# ក្បួនទី១វិធីដោះស្រាយ:
# សមីការនិងវិសមីការមួយចំនួន

✴ **វិធីសាស្ត្រទី១:** ដោះស្រាយសមីការនិង វិសមីការមានតំលៃដាច់ខាត:

១. **និយមន័យ:** $\forall x \in \mathbf{IR}$ គេកំណត់ $|x|$ ជាតំលៃដាច់ខាតនៃ $x$ ដែល:

$$|x| = \begin{cases} x \text{ if } x \geq 0 \\ -x \text{ if } x < 0 \end{cases}$$

២. **លក្ខណ:**

$a. |x| = 0 \Rightarrow x = 0$

$b. |x| = |-x|$

$c. |xy| = |x||y|$

$d. \dfrac{|x|}{|y|} = \left|\dfrac{x}{y}\right|$

$e.$ បើ $\alpha \geq 0$ និង $|x| < \alpha \Rightarrow -\alpha \leq x \leq \alpha$

$f.$ បើ $x$ ជាចំនួនពិតនោះគេបាន: $-|x| \leq x \leq |x|$

$.|x+y| \leq |x| + |y|$

$.|x+y| \geq |x| - |y|$

✍ **វិធីដោះស្រាយ:**

$a. |A| = |B| \Leftrightarrow A^2 = B^2 \Leftrightarrow A = \pm B$

$b. |A| = B \Leftrightarrow \begin{cases} B \geq 0 \\ A = \pm B \end{cases} \Leftrightarrow \begin{cases} A \geq 0 \\ A = B \end{cases} V \begin{cases} A < 0 \\ A = -B \end{cases}$

$$c.|A|<B \Leftrightarrow \begin{cases} -B<A<B \\ B>0 \end{cases} \Leftrightarrow \begin{cases} B>0 \\ A^2<B^2 \end{cases}$$

$$\Leftrightarrow \begin{cases} A\geq 0 \\ A<B \end{cases} V \begin{cases} A<0 \\ A>-B \end{cases}$$

$$d.|A|>B \Leftrightarrow \left[\begin{array}{l} A>B \\ A<-B \end{array}\right. \Leftrightarrow \begin{cases} A\geq 0 \\ A>B \end{cases} V \begin{cases} A<0 \\ A<-B \end{cases}$$

$$\Leftrightarrow B<0 \ V \begin{cases} B\geq 0 \\ A^2>B^2 \end{cases}$$

$$e.|A|>|B| \Leftrightarrow |A|^2>|B|^2$$

✯ **វិធីសាស្ត្រទី២:** សមីការរាង:

$$a\left(x^2+\frac{1}{x^2}\right)+b\left(x+\frac{1}{x}\right)+c=0(*)$$

✍ ***វិធីដោះស្រាយ:***

តាង $t=x+\frac{1}{x} \Rightarrow t\leq -2 \ v \ t\geq 2, \ \forall x\neq 0$ នោះគេបាន(*):

$$\Leftrightarrow \begin{cases} t\leq -2 v \ t\geq 2 \\ at^2+bt+c-2a=0 \end{cases}$$

រួចដោះស្រាយសមីការដឺក្រេទី២ជាការស្រេច ។

✯ **វិធីសាស្ត្រទី៣:** សមីការរាង:

$$a\left(x^2-\frac{1}{x^2}\right)+b\left(x-\frac{1}{x}\right)+c=0(*)$$

✍ ***វិធីដោះស្រាយ:***

តាង $t = x - \frac{1}{x}$ ដែល $t \in \mathbf{IR}, \forall x \neq 0$ គេបាន(*)ទៅជា:

$$at^2 + bt + c + 2a = 0$$

✵ **វិធីសាស្ត្រទី៤:**សមីការរាង: $at^4 + bx^2 + c = 0 \left( a \neq 0 \right) \ (*)$

✍ ***វិធីដោះស្រាយ:*** តាង $t = x^2$ ; ដែល $t \geq 0$ នោះ $(*)$ ទៅជា:

$$at^2 + bt + c = 0 \quad (\text{ការេស្មូទង់})$$ ។

✵ **វិធីសាស្ត្រទី៥:**.សមីការរាង:

$$\left( x + a \right)^4 + \left( x + b \right)^4 = k \ , \left( k \neq 0 \right) (*)$$

✍ ***វិធីដោះស្រាយ:*** តាង $t = x + \frac{a+b}{2} \Leftrightarrow x = t - \frac{a+b}{2}$

នោះគេបាន: $\left[ \begin{array}{l} x + a = t + \frac{a-b}{2} \\ x + b = t - \frac{a-b}{2} \end{array} \right.$ ចំពោះ

$\alpha = \frac{a-b}{2}$ គេបានសមីការ:

$$t^4 + 12\alpha^2 + t^2 + 2\alpha^4 - k = 0$$

$$\Leftrightarrow t^4 + t^2 + \left( 2\alpha^4 + 12\alpha^2 - k \right) = 0; \left( \alpha = \frac{a-b}{2} \right)$$

✵ **វិធីសាស្ត្រទី៦:**.សមីការរាង:

$$\left( x - a \right)^4 + \left( x - b \right)^4 = k \ , \left( k \neq 0 \right) (*)$$

✍ ***វិធីដោះស្រាយ:*** តាង $t = x - \frac{a+b}{2}$ ( **ធ្វើដូចវិធីសាស្ត្រ**5)

✳ **វិធីសាស្ត្រទី៧:**.សមីការរាង:

$$(x+a)(x+b)(x+c)(x+d) = k, (*)$$

**(សមីការឆ្លុះ)**

ដែលក្នុងនោះ : $a+b = c+d, k \neq 0$

✍ ***វិធីដោះស្រាយ:*** តាង $t = (x+a)(x+b)$ រឺ

$t = x^2 + (a+b)x + e$ ដែល $e \in \mathbf{IR}$

ហើយ $t \geq -\frac{(a-b)^2}{4}$ នោះសមីការទៅជា:

$$t^2 + (cd - ab)t - k = 0$$

✳ **វិធីសាស្ត្រទី៨:** សមីការរាង:

$$ax^4 + bx^3 + cx^2 \pm bx + a = 0, (a \neq 0)(*)$$

✍ ***វិធីដោះស្រាយ:***

+ចំពោះ $x = 0$ មិនមែនជារឹសនៃសមីការ(*)

យើងចែកអង្គទាំងពីរនិង $x^2$ ដែល $x^2 \neq 0$ គេបាន:

$a\left(x^2 + \frac{1}{x^2}\right) + b\left(x \pm \frac{1}{x}\right) + c = 0$ យើងតាង:

$t = x \pm \frac{1}{x} \Rightarrow x^2 + \frac{1}{x^2} = t^2 \pm 2$

គេបានសមីការទៅជា:

$$at^2 + bt + c \pm 2a = 0$$

បើ $t = x + \frac{1}{x}$ គេបាន: $|t| \geq 2$

បើ $t = x - \frac{1}{x}$ គ្មានលក្ខខណ្ឌ $t$ ។

✳ **<u>វិធីសាស្ត្រទី៩:</u>** សមីការរាង:

$$ax^4 + bx^3 + cx^2 + dx + e = 0 \text{ , } (*)$$

ចំពោះ: $\frac{e}{a} = \left(\frac{d}{b}\right)^2$

**<u>ករណីពិសេសបើ:</u>** $\begin{cases} e = a \\ b = \pm d \end{cases}$ គេបានសមីការទៅជា:

$$ax^4 + bx^3 + cx^2 \pm bx + a = 0$$

✍ ***<u>វិធីដោះស្រាយ:</u>*** ចែកអង្គទាំងពីរនិង $x^2 \neq 0$ នោះគេបាន:

$$a\left(x^2 + \frac{1}{x^2}\right) + b\left(x \pm \frac{1}{x}\right) + c = 0$$

តាង $t = x \pm \frac{1}{x}$ ដោះស្រាយដូចH ។

✳ **<u>វិធីសាស្ត្រទី១០:</u>**.សមីការរាង:

$$\frac{mx}{ax^2 + bx + c} + \frac{nx}{ax^2 + b'x + c} = k, \ (k \neq 0); (*)$$

✍ ***<u>វិធីដោះស្រាយ:</u>***

បើ $x=0$ មិនមែនជាឫសនៃសមីការទេ យើងចែកអង្គខាង

ឆ្វេងសមីការ(*)និង $x$ :

$$\frac{m}{ax+\frac{c}{x}+b}+\frac{n}{ax+\frac{c}{x}+b'}=k$$ តាង $t=ax+\frac{c}{x}$ រកលក្ខខណ្ឌនៃ

$t$ នោះសមីការទៅជា: $\frac{m}{t+b}+\frac{n}{t+b'}=k$ ។

✴ **វិធីសាស្ត្រទី១១:**.សមីការរាង:

$$\alpha(x+a)(x+b)+\beta(x+a)\sqrt{\frac{x+b}{x+a}}=k(*)$$

✍ **វិធីដោះស្រាយ:**យើងតាង: $t=(x+a)\sqrt{\frac{x+b}{x+a}}$

រកលក្ខខណ្ឌនៃ $x$ នោះគេបាន:

$$\Rightarrow t^2=(x+a)(x+b)$$ សមីការ(*)ទៅជា:

$$\alpha t^2+\beta t=k$$ ។

✴ **វិធីសាស្ត្រទី១២:**សមីការរាង:

$$\alpha\sqrt[n]{(a+x)^2}+\beta\sqrt[n]{a^2-x^2}+\alpha\sqrt[n]{(a-x)^2}=0(*)$$

(ដែល $n$ ជាចំនួនគត់វិជ្ជមានសេស)

✍ **វិធីដោះស្រាយ:**

ឧបមា $\alpha\neq 0$ ចែកអង្គទាំងពីរនិង $\sqrt[n]{(a-x)^2}\neq 0$ នោះគេបាន:

$$\alpha\sqrt[n]{\left(\frac{a+x}{a-x}\right)^2}+\beta\sqrt[n]{\frac{a+x}{a-x}}+\alpha=0$$ នោះយើងត្រូវតាង

$t=\sqrt{\frac{a+x}{a-x}}$ នោះគេបានសមីការ(*)ទៅជា: $\alpha t^2+\beta t+\alpha=0$ ។

✶ **<u>វិធីសាស្ត្រទី១៣:</u>** សមីការរាង:

$$ax^3+bx^2+cx+d=0\ (a\neq 0)\ (*)$$

✎ ***<u>វិធីដោះស្រាយ:</u>***

បើសមីការ(*)រាង:

$a+b+c+d=0$ នោះវាមានរឹស $x=1$

ប្រើវិធីចែកពហុធា:

$ax^3+bx^2+cx+d$ និង $(x-1)$ នោះគេបាន:

$Ax^2+Bx+C$ យើងសរសេរ:

$$ax^3+bx^2+cx+d=(x-1)\left(Ax^2+Bx+C\right)=0$$

$$\Leftrightarrow\left[\begin{array}{l}x-1=0\Rightarrow x=1(1)\\ Ax^2+Bx+C=0(2)\end{array}\right.$$

បើសមីការ(*)រាង: $a-b+c-d=0\Leftrightarrow a+c=b+d$

នោះសមីការមានរឹស $x=-1$

ចែកពហុធាដូច(L)គេបាន:

$$\Leftrightarrow \left[\begin{array}{l} x+1=0 \Rightarrow x=-1 (1) \\ Ax^2+Bx+C=0 (2) \end{array}\right.$$

បើមិនចូលរាងពិសេសខាងលើនោះយើងជំនួស $x=\alpha$ ក្នុងស
មីការមានរឹសផ្ទៀងផ្ទាត់នោះ $\alpha$ ជារឹស ។

ចែកពហុធាដូច(L និងM)គេបានៈ

$$ax^3+bx^2+cx+d=(x-\alpha)\left(Ax^2+Bx+C\right)=0$$

$$\Leftrightarrow \left[\begin{array}{l} x-\alpha=0 \Rightarrow x=\alpha (1) \\ Ax^2+Bx+C=0 (2) \end{array}\right.$$

<u>យើងអាចប្រើវិធីដាក់កត្តាៈ</u>

$$ax^3+bx^2+cx+d=(px+q)\left(Ax^2+Bx+C\right)=0$$

$$\Leftrightarrow \left[\begin{array}{l} px+q=0 (1) \\ Ax^2+Bx+C=0 (2) \end{array}\right.$$

✵ **<u>វិធីសាស្ត្រទី១៤</u>**ៈសមីការអសនិទានៈ

✍ **<u>វិធីដោះស្រាយៈ</u>**

$$* \sqrt[2n]{f(x)}=g(x) \Leftrightarrow \left\{\begin{array}{l} g(x) \geq 0 \\ f(x)=\left[g(x)\right]^{2n} \end{array}\right.$$

$$* \sqrt[2n+1]{f(x)}=g(x) \Leftrightarrow f(x)=\left[g(x)\right]^{2n+1}$$

* $[f(x)]^{2n} = [g(x)]^{2n} \Leftrightarrow |f(x)| = |g(x)|$

* $[f(x)]^{2n+1} = [g(x)]^{2n+1} \Leftrightarrow f(x) = g(x)$

✴ **វិធីសាស្ត្រទី១៥:** សមីការមានរាង: $\frac{1}{1+a^2};\frac{2a}{1+a^2};\frac{1-a^2}{1+a^2};... \forall x \in IR$

✍ **វិធីដោះស្រាយ:** យើងតាង: $a = \tan\alpha, \alpha \in \left]-\frac{\pi}{2};\frac{\pi}{2}\right[$

✴ **វិធីសាស្ត្រទី១៦:** សមីការមានរាង: $x^2 + y^2 = a^2$

✍ **វិធីដោះស្រាយ:** យើងតាង: $\begin{cases} x = a\cos t \\ y = a\sin t \end{cases}; -\pi \le t \le \pi$

+បើ $f(x) \le M, \forall x \in D \Leftrightarrow Max f \le M$

+បើ $f(x) \ge m, \forall x \in D \Leftrightarrow Min f \ge m$

## ក្បួនទី២វិធីដោះស្រាយៈ
## សមីការនិងវិសមីការអិចស្ប៉ូណង់ស្យែល

✴ **វិធីសាស្ត្រទី១:** សមីការរាង: $a^{f(x)} = a^{g(x)}; (a > 0, a \neq 0)$

✍ ***វិធីដោះស្រាយ:*** នោះគេបាន: $f(x) = g(x)$ រួចយើងដោះស្រាយ សមីការនេះជាការស្រេច។

✵ **វិធីសាស្ត្រទី២:** សមីការរាង: $\alpha a^{2f(x)}+\beta a^{f(x)}+\gamma=0$

$(a>0, a\neq 1, \alpha,\beta,\gamma\in IR)$

✍ ***វិធីដោះស្រាយ:*** យើងតាង: $t=a^{f(x)}>0$ នោះសមីការទៅជា:

$\alpha t^2+\beta t+\gamma=0$ រួចយើងដោះស្រាយសមីការដឺក្រេទី២ ។

✵ **វិធីសាស្ត្រទី៣:** សមីការរាង:

$$\alpha a^{2f(x)}+\beta(ab)^{f(x)}+\gamma b^{2f(x)}=0$$

$$(a>0, a\neq 1, b>0, b\neq 1)$$

✍ ***វិធីដោះស្រាយ:*** យើងចែកអង្គទាំងពីរនិង $b^{2f(x)}$ នោះគេបាន:

$\alpha\left(\frac{a}{b}\right)^{2f(x)}+\beta\left(\frac{a}{b}\right)^{f(x)}+\gamma=0$ បន្ទាប់មកយើងតាង:

$t=\left(\frac{a}{b}\right)^{f(x)}, t>0$ នោះសមីការខាងលើទៅជា: $\alpha t^2+\beta t+\gamma=0$

✵ **វិធីសាស្ត្រទី៤:** សមីការរាង: $a_1^{f(x)}+a_2^{f(x)}=\alpha$ ចំពោះ $a_1.a_2=1$

និង $a_1>0, a_2>0, a_1\neq 1; a_2\neq 1, \alpha\in IR^*_+$

✍ ***វិធីដោះស្រាយទី១:***

យើងតាង: $t=a_1^{f(x)}; t>0\left(t=a_2^{f(x)}>0\right)$ ដោយ

$a_1.a_2=1\Rightarrow a_2=\frac{1}{a_1}\Rightarrow a_2^{f(x)}=\frac{1}{a_1^{f(x)}}=\frac{1}{t}$ នោះសមីការទៅជា:

$t+\frac{1}{t}=\alpha\Rightarrow t^2-\alpha t+1=0$ រួចយើងដោះស្រាយសមីការដឺក្រេទី២ ។

✍ ***វិធីដោះស្រាយទី២:*** ចំពោះ $a_1^{f(x)}+a_2^{f(x)}=\alpha$ យើងតាង:

$u = a_1^{f(x)}$ និង $v = a_2^{f(x)}; u > 0, v > 0$ គេបាន: $\begin{cases} u + v = a \\ u.v = 1 \end{cases}$ រួចយើង

ដោះស្រាយរកតំលៃរបស់ $u$ និង $v$ ។

✳ **<u>វិធីសាស្ត្រទី៥:</u>** សមីការរាង: $a^x + b^x = c^x$

ដែល $a, b, c > 0; a, b, c \neq 1$ យើងកំនត់ចំណាំថា: $a^2 + b^2 = c^2$ (មានន័យ

ថា $a, b, c$ ជារង្វាស់ជ្រុងរបស់ត្រីកោណកែងដែលមាន $c$ ជាអ៊ីប៉ូតេនុស) ។

យើងចែកអង្គទាំងពីរនិង $c^x > 0$ គេបាន: $\left(\frac{a}{c}\right)^x + \left(\frac{b}{c}\right)^x = 1 (*)$

យើងសង្កេតឃើញថាសមីការមានរឹស: $x = 2$ ដោយហេតុថា:

$\left(\frac{a}{b}\right)^2 + \left(\frac{b}{c}\right)^2 = \frac{a^2 + b^2}{c^2} = 1$ យើងនិងស្រាយថាសមីការមានរឹស $x = 2$ តែ

មួយគត់ ។

✎ ***<u>វិធីដោះស្រាយទី១:</u>*** យើងប្រើវិសមភាពមកដោះស្រាយដូចខាងក្រោម:

+**បើ** $x < 2$ នោះគេបាន:

$$+\begin{cases} \left(\frac{a}{c}\right)^x > \left(\frac{a}{c}\right)^2 \\ \left(\frac{b}{c}\right)^x > \left(\frac{b}{c}\right)^2 \end{cases}$$

$$\left(\frac{a}{c}\right)^x + \left(\frac{b}{c}\right)^x > 1 \Rightarrow x < 2$$

នោះ $x < 2$ មិនមែនជារឹសនៃសមីការទេ ។

+បើ $x > 2$ នោះគេបាន:

$$+\begin{cases}\left(\frac{a}{c}\right)^x < \left(\frac{a}{c}\right)^2 \\ \left(\frac{b}{c}\right)^x < \left(\frac{a}{c}\right)^2\end{cases}$$

$$\left(\frac{a}{c}\right)^x + \left(\frac{b}{c}\right)^x < 1 \Rightarrow x > 2$$

នោះ $x > 2$ មិនមែនជាឫសនៃសមីការទេ ។

យើងអាចសន្និដ្ឋានបានថា: មានតែ $x = 2$ ប៉ុណ្ណោះជាឫស ។

✍ ***វិធីដោះស្រាយទី២:*** យើងនិងប្រើតាមលក្ខណៈនៃអនុគមន៍:

ដំបូងយើងតាង: $y = \left(\frac{a}{c}\right)^x + \left(\frac{b}{c}\right)^x$ ដែលយើងសង្កេតឃើញថា: $y$ ជាអនុគមន៍ចុះដាច់ខាងព្រោះ: $0 < \frac{a}{c}; \frac{b}{c} < 1$ ក៏ប៉ុន្តែសមីការដើមគឺ:

$\left(\frac{a}{c}\right)^x + \left(\frac{b}{c}\right)^x = 1$ មានន័យថា: $y = 1$ ដែលជាអនុគមន៍ថេរ ។

តាមករណីទាំងពីរយើងសង្កេតឃើញថា:ខ្សែកោងតាងអនុគមន៍ទាំងពីរកាត់គ្នាតែមួយគត់មានអាប់ស៊ីស $x = 2$ ។ ដូចនេះ $x = 2$ ជាឫសតែមួយគត់នៃសមីការ ។

✍ ***វិធីដោះស្រាយទី៣:*** ការប្រើអនុគមន៍ត្រីកោណមាត្រមកដោះស្រាយ:

យើងតាង: $\frac{a}{c}; \frac{b}{c}$ ដោយ $\sin\alpha$ និង $\cos\alpha$ នៃមុំណាមួយក៏បាន:

បើយើងតាង: $\sin a = \frac{a}{c} \Rightarrow \cos a = \frac{b}{c}$ ព្រោះ: $\cos^2 a = 1 - \sin^2 a$

$$\sin^2 a + \cos^2 a = 1 \Rightarrow \cos^2 a = 1 - \sin^2 a$$

$$\cos^2 a = 1 - \frac{a^2}{c^2} = \frac{c^2 - a^2}{c^2} = \frac{b^2}{c^2} \Rightarrow \cos a = \frac{b}{c}$$

$$\Rightarrow \begin{cases} (\sin a)^x + (\cos a)^x = 1 \\ (\sin a)^2 + (\cos a)^2 = 1 \end{cases} \Rightarrow x = 2$$

✵ **វិធីសាស្ត្រទី៦:** សមីការរាង $a^{f(x)} + a^{g(x)} = a^{h(x)} + 1 \left(a > 0; a \neq 1\right)$

✎ **វិធីដោះស្រាយ:** យើងតាង: $u = a^{f(x)}, u > 0$ និង $v = a^{g(x)}, v > 0$

$\Rightarrow u.v = a^{f(x)}.a^{g(x)} = a^{f(x)+g(x)} = a^{h(x)}$ ដូចនេះសមីការទៅជា:

$$u + v = uv + 1$$

$$\Leftrightarrow u + v - uv - 1 = 0$$

$$\Leftrightarrow u - 1 - v(u - 1) = 0$$

$$\Leftrightarrow (u - 1)(1 - v) = 0$$

$$\Rightarrow \begin{cases} u - 1 = 0 \\ 1 - v = 0 \end{cases} \Leftrightarrow \begin{cases} u = 1 \\ v = 1 \end{cases}$$

$$\Leftrightarrow \begin{cases} a^{f(x)} = 1 \\ a^{g(x)} = 1 \end{cases} \Leftrightarrow \begin{cases} f(x) = 0 \\ g(x) = 0 \end{cases}$$

✵ **វិធីសាស្ត្រទី៧:** សមីការរាង: $a^{f(x)} + a^{g(x)} = a^{h(x)} + 1 \left(a > 0; a \neq 0\right)$

ចំពោះ: $f(x) - g(x) = h(x)$

✎ **វិធីដោះស្រាយ:** យើងតាង: $u = a^{f(x)}, u > 0$ និង $v = a^{g(x)}, v > 0$

គេបាន: $\frac{u}{v} = \frac{a^{f(x)}}{a^{g(x)}} = a^{f(x)-g(x)} = a^{h(x)}$ ដូចនេះគេបានសមីការទៅជា:

$$u+v=\frac{u}{v}+1$$

$$\Leftrightarrow (u+v)-\left(\frac{u+v}{v}\right)=0$$

$$\Leftrightarrow (u+v)\left(1-\frac{1}{v}\right)=0$$

$\Rightarrow 1-\frac{1}{v}=0$ ព្រោះ $(u+v>0)$

$$\Rightarrow v=1$$

$$\Leftrightarrow a^{g(x)}=1 \Rightarrow g(x)=0$$

✳ **វិធីសាស្ត្រទី៨:** សមីការរាង: $\left[A(x)\right]^{m(x)}=1$

✍ ***វិធីដោះស្រាយ:*** ចំពោះសមីការប្រភេទនេះយើងត្រូវធ្វើទៅលើពីរករណីជាការ ចាំបាច់:

***ដំណោះស្រាយតាមការនិតៀន:*** ចំពោះករណីនេះយើងអាចសរសេរ:

$\begin{cases} A(x)=1 \\ m(x)\ \text{មានន័យ} \end{cases}$ ចំលើយ(១)

***ដំណោះស្រាយសមីការអ៊ិចស្ប៉ូណង់ស្យែល:*** តាមករណីនេះគេបាន:

$\begin{cases} A(x)>0 \\ A(x)\neq 0 \\ m(x)=0 \end{cases}$ ចំលើយ(2)

**ចំលើយសរុបគឺចំលើយ:** $(1)\cup(2)$ ។

✳ **វិធីសាស្ត្រទី៨:** សមីការរាង: $\left[a(x)\right]^{f(x)}=\left[a(x)\right]^{g(x)}$

✍ ***វិធីដោះស្រាយ:*** ចំពោះសមីការប្រភេទនេះគេបាន:

$$\begin{cases} a(x) > 0 \\ [a(x) - 1][f(x) - g(x)] = 0 \end{cases}$$

**ចំពោះវិសមីការអ៊ិចស្ប៉ូណង់ស្យែល**

**ចំពោះករណីទី១:** ចំពោះ $a > 1$

✳ **វិធីសាស្ត្រទី១:** វិសមីការរាង: $a^{f(x)} > a^{g(x)}$ បើ $a > 1$

✍ ***វិធីដោះស្រាយ:*** យើងអាចទាញបានថា: $f(x) > g(x)$

✳ **វិធីសាស្ត្រទី២:** វិសមីការរាង: $a^{f(x)} \geq a^{g(x)}$ បើ $a > 1$

✍ ***វិធីដោះស្រាយ:*** យើងទាញបានថា: $f(x) \geq g(x)$

**ចំពោះករណីទី២:** បើ $0 < a < 1$

✳ **វិធីសាស្ត្រទី៣:** វិសមីការរាង: $a^{f(x)} < a^{g(x)}$

✍ ***វិធីដោះស្រាយ:*** យើងទាញបាន: $f(x) > g(x)$

✳ **វិធីសាស្ត្រទី៤:** វិសមីការរាង: $a^{f(x)} \leq a^{g(x)}$

✍ ***វិធីដោះស្រាយ:*** យើងទាញបាន: $f(x) \geq g(x)$

✳ **វិធីសាស្ត្រទី៥:** បើ $U$ ជាអនុគមន៍ដែលមានអញ្ញាតិណាមួយនោះចំពោះសមីការ ដែលមានរាង: $U(x)^{f(x)} > U(x)^{g(x)}$ គេបាន:

✍ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះយើងត្រូវដោះស្រាយតាមរបៀបខាងក្រោមនេះ:

$$\begin{cases} U > 0 \quad (1) \\ (U-1)\left[f(x)-g(x)\right] > 0 \quad (2) \end{cases}$$

ដូចនេះចំលើយរបស់វិសមីការគឺជាប្រសព្វរវាង: $(1)$និង$(2)$ ។

✵ **វិធីសាស្ត្រទី៦:** វិសមីការរាង: $U^{f(x)} \geq U^{g(x)}$

✍ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះយើងត្រូវដោះស្រាយតាមរបៀបខាងក្រោមនេះ:

$$\begin{cases} U > 0 \quad (1) \\ (U-1)\left[f(x)-g(x)\right] \geq 0 \quad (2) \end{cases}$$

ដូចនេះចំលើយរបស់វិសមីការគឺជាប្រសព្វរវាង: $(1)$និង$(2)$ ។

✵ **វិធីសាស្ត្រទី៧:** វិសមីការរាង: $U(x)^{f(x)} < 1$

✍ **វិធីដោះស្រាយ:** ចំពោះវិសមីការនេះយើងត្រូវដោះស្រាយតាមរបៀបខាងក្រោមនេះ:

$$\left[\begin{array}{l} \begin{cases} U-1>0 \\ f(x)<0 \end{cases} \quad (I) \\ \begin{cases} U>0 \\ U-1<0 \\ f(x)>0 \end{cases} \quad (II) \end{array}\right.$$

**ដូចនេះចំលើយនៃវិសមីការគឺជាប្រជុំរវាង:** $(I) \cup (II)$ ។

# ក្បួនទី៤ចំពោះសមីការនិងវិសមីការលោការីត

## ចំពោះសមីការលោការីត

✳ **វិធីសាស្ត្រទី១:** សមីការរាង: $\lg_a f(x) = g(x)$

✍ ***វិធីដោះស្រាយ:*** ចំពោះសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} a > 0; a \neq 1 \\ f(x) > 0 \\ f(x) = a^{g(x)} \end{cases}$$

✳ **វិធីសាស្ត្រទី២:** សមីការរាង: $\lg_a f(x) = \lg_a g(x)$

✍ ***វិធីដោះស្រាយ:*** ចំពោះសមីការនេះវិធីសាស្ត្រត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} a > 0; a \neq 1 \\ f(x) > 0; g(x) > 0 \\ f(x) = g(x) \end{cases}$$

## ចំពោះវិសមីការលោការីត

✳ **វិធីសាស្ត្រទី១:** វិសមីការរាង: $\lg_a f(x) \geq \lg_a g(x)$ ចំពោះ: $a > 1$

✍ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} a > 1 \\ f(x) > 0 \\ g(x) > 0 \\ f(x) \geq g(x) \end{cases}$$

✱ **វិធីសាស្ត្រទី២:** វិសមីការរាង: $\lg_a f(x) \geq \lg_a g(x)$ ចំពោះ $0 < a < 1$

✎ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} f(x) > 0 \\ g(x) > 0 \\ f(x) \leq g(x) \end{cases}$$

✱ **វិធីសាស្ត្រទី៣:** វិសមីការរាង: $\lg_{g(x)} f(x) > \lg_{g(x)} h(x)$

✎ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} g(x) > 0; g(x) \neq 1 \\ f(x) > 0 \\ g(x) > 0 \\ \left[g(x) - 1\right]\left[f(x) - h(x)\right] > 0 \end{cases}$$

✱ **វិធីសាស្ត្រទី៤:** វិសមីការរាង: $\lg_{g(x)} f(x) < \lg_{g(x)} h(x)$

✎ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} g(x) > 0; g(x) \neq 1 \\ f(x) > 0 \\ g(x) > 0 \\ \left[g(x) - 1\right]\left[f(x) - h(x)\right] < 0 \end{cases}$$

✵ **វិធីសាស្ត្រទី៥:** វិសមីការរាង: $\lg_{g(x)} f(x) \geq \lg_{g(x)} h(x)$

✍ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} g(x) > 0; g(x) \neq 1 \\ f(x) > 0 \\ g(x) > 0 \\ \left[g(x)-1\right]\left[f(x)-h(x)\right] \geq 0 \end{cases}$$

✵ **វិធីសាស្ត្រទី៦:** វិសមីការរាង: $\lg_{g(x)} f(x) \leq \lg_{g(x)} f(x)$

✍ ***វិធីដោះស្រាយ:*** ចំពោះវិសមីការនេះវិធីដោះស្រាយត្រូវធ្វើដូចខាងក្រោម:

$$\begin{cases} g(x) > 0; g(x) \neq 1 \\ g(x) > 0 \\ f(x) > 0 \\ \left[g(x)-1\right]\left[f(x)-h(x)\right] \leq 0 \end{cases}$$

✵ **វិធីសាស្ត្រទី៧:** វិសមីការរាង: $\lg_{A(x)} f(x) < 1$

✍ **វិធីដោះស្រាយ:**

ចំពោះវិសមីការនេះយើងត្រូវដោះស្រាយតាមរបៀបខាង ក្រោមនេះ:

$$\begin{cases} A(x)-1 > 0 \\ f(x) > 0 \\ \dfrac{f(x)}{A(x)} > 0 \\ \dfrac{f(x)}{A(x)} - 1 < 0 \end{cases} \quad (I) \quad \text{ឬ} \quad \begin{cases} A(x) > 0 \\ A(x)-1 < 0 \\ f(x) > 0 \\ \dfrac{f(x)}{A(x)} - 1 > 0 \end{cases} \quad (II)$$

ដូចនេះចំលើយនៃវិសមីការគឺជាប្រជុំរវាង:$(I)\cup(II)$ ។

## ក្បួនទី៥:ការដោះស្រាយសមីការត្រីកោណមាត្រ

✶ **វិធីសាស្ត្រទី១:**សមីការរាង:$\sin x = \sin\alpha$

✍ **វិធីដោះស្រាយ:**ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

$$\Rightarrow \begin{cases} x = \alpha + 2k\pi \\ x = \pi - \alpha + 2k\pi \end{cases}$$

✶ **វិធីសាស្ត្រទី២:**សមីការរាង:$\cos x = \cos\alpha$

✍ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

$$\Rightarrow \quad x = \pm\alpha + 2k\pi$$

✶ **វិធីសាស្ត្រទី៣:**សមីការរាង:$\tan x = \tan\alpha$

✍ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

$$\Rightarrow \begin{cases} x = \alpha + k\pi \\ x \neq \dfrac{\pi}{2} + k\pi \end{cases}$$

✶ **វិធីសាស្ត្រទី៤:**សមីការរាង:$\cot x = \cot\alpha$

✍ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

$$\Rightarrow \begin{cases} x = \alpha + k\pi \\ x \neq k\pi \end{cases}$$

✳ **វិធីសាស្ត្រទី៥:** សមីការរាង: $a\sin x + b = 0\ (a \neq 0)$

✎ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងមានសមីការ: $a\sin x + b = 0\ (a \neq 0)$ យើងទាញបាន:

$\Rightarrow \sin x = -\frac{b}{a}$ បន្ទាប់មកយើងតាង: $\sin\alpha = -\frac{b}{a}; (-1 \leq \sin\alpha \leq 1)$

នោះសមីការទៅជា: $\sin x = \sin\alpha$ ដោះស្រាយតាមវិធីសាស្ត្រខាងលើ ។

✳ **វិធីសាស្ត្រទី៦:** សមីការរាង: $a\cos x + b = 0(a \neq 0)$

✎ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងមានសមីការ: $a\cos x + b = 0(a \neq 0)$ យើងទាញបាន:

$\Rightarrow \cos x = -\frac{b}{a}$ បន្ទាប់មកយើងតាង: $\cos\alpha = -\frac{b}{a}; (-1 \leq \cos\alpha \leq 1)$

នោះសមីការទៅជា: $\cos x = \cos\alpha$ ដោះស្រាយតាមវិធីសាស្ត្រខាងលើ ។

✳ **វិធីសាស្ត្រទី៧:** សមីការរាង: $a\tan x + b = 0(a \neq 0)$

✎ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងមានសមីការ: $a\tan x + b = 0(a \neq 0)$ យើងទាញបាន:

$\Rightarrow \tan x = -\frac{b}{a}$ បន្ទាប់មកយើងតាង: $\tan \alpha = -\frac{b}{a}\left(\alpha \neq \frac{\pi}{2} + k\pi\right)$ នោះ

សមីការទៅជា: $\tan x = \tan \alpha$ ដោះស្រាយតាមវិធីសាស្ត្រខាងលើ ។

✵ **វិធីសាស្ត្រទី៨:** សមីការរាង: $a\cot x + b = 0(a \neq 0)$

✍ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងមានសមីការ: $a\cot x + b = 0(a \neq 0)$ យើងទាញបាន:

$\Rightarrow \cot x = -\frac{b}{a}$ បន្ទាប់មកយើងតាង: $\cot \alpha = -\frac{b}{a}(\alpha \neq k\pi)$ នោះ

សមីការទៅជា: $\cot x = \cot \alpha$ ដោះស្រាយតាមវិធីសាស្ត្រខាងលើ ។

✵ **វិធីសាស្ត្រទី៩:** សមីការរាង: $a\sin^2 x + b\sin x + c = 0(a \neq 0)$

✍ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងតាង: $y = \sin x(-1 \leq y \leq 1)$ នោះសមីការទៅជា:

$ay^2 + by + c = 0$ រួចយើងដោះស្រាយសមីការនេះដោយជ្រើសរើសតែរឹស

ណាដែលផ្ទៀងផ្ទាត់ $|y| \leq 1$ ។

✵ **វិធីសាស្ត្រទី១០:** សមីការរាង: $a\cos^2 x + b\cos x + c = 0(a \neq 0)$

✍ **វិធីដោះស្រាយ:**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងតាង: $y = \cos x(-1 \leq y \leq 1)$ នោះសមីការទៅជា:

$ay^2+by+c=0$ ដោះស្រាយដូចវិធីសាស្ត្រខាងលើ ។

✳ **<u>វិធីសាស្ត្រទី១១:</u>**សមីការរាង: $atg^2x+tgx+c=0\,(a\neq 0)$

✎ **<u>វិធីដោះស្រាយ:</u>**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងតាង: $y=tgx$ នោះសមីការទៅជា:

$ay^2+by+c=0$ ដោះស្រាយដូចវិធីសាស្ត្រខាងលើ ។

✳ **<u>វិធីសាស្ត្រទី១២:</u>**សមីការរាង: $a\cot^2x+b\cot x+c=0\,(a\neq 0)$

✎ **<u>វិធីដោះស្រាយ:</u>**

ចំពោះសមីការនេះយើងប្រើដំណោះស្រាយដូចខាងក្រោម:

យើងតាង: $y=\cot x$ នោះសមីការទៅជា:

$ay^2+by+c=0$ ដោះស្រាយដូចវិធីសាស្ត្រខាងលើ ។

✳ **<u>វិធីសាស្ត្រទី១៣:</u>**សមីការរាង: $a\cos x+b\sin x=c$ ដែលយើងដឹងថា: $(a,b,c\neq 0)$ហើយ $a^2+b^2\geq c^2$ ។

ចំពោះវិធីដោះស្រាយយើងអាចដោះស្រាយបានតាមពីររបៀបខាងក្រោម:

✎ **<u>វិធីដោះស្រាយទី១:</u>**ការប្រើវិធីត្រីកោណមាត្រ:

យើងចែកអង្គទាំងពីរនិង $a$ រួចតាង: $\frac{b}{a}=tg\alpha\left(-\frac{\pi}{2}<\alpha<\frac{\pi}{2}\right)$ពេលនោះ

សមីការ $\cos x+\frac{b}{a}\sin x=\frac{c}{a}\Leftrightarrow\cos x+tg\alpha\sin x=\frac{c}{a}$

$$\Leftrightarrow\cos x\cos\alpha+\sin\alpha\sin x=\frac{c}{a}\cos\alpha$$

$\Leftrightarrow \cos(x-\alpha)=\frac{c}{a}\cos\alpha$ សន្មតយក: $\frac{c}{a}\cos\alpha=\cos\lambda$

$\Rightarrow \cos(x-\alpha)=\cos\lambda$ យើងដោះស្រាយសមីការនេះជាការស្រេច

✎ **វិធីដោះស្រាយទី២:** ការប្រើអញ្ញាតជំនួយវិធីពីជគណិត

យើងតាង: $t=tg\frac{x}{2};(x\neq 2k+1)$ នោះយើងបាន: $\cos x=\frac{1-t^2}{1+t^2}$ និង $\sin x=\frac{2t}{1+t^2}$ នោះសមីការខាងលើទៅជា:

$(a+c)t^2-2bt+c-a=0$ យើងដោះស្រាយសមីការនេះយើងបានរឹសពីរគឺ $t_1$ និង $t_2$ ។យើងតាង: $\begin{cases} t_1=tg\alpha_1 \\ t_2=tg\alpha_2 \end{cases}$ ពេលនោះយើងបាន:

+បើ $tg\frac{x}{2}=tg\alpha_1 \Rightarrow x=2\alpha_1+2k\pi$

+បើ $tg\frac{x}{2}=tg\alpha_2 \Rightarrow x=2\alpha_2+2k\pi$

✲ **វិធីសាស្ត្រទី១៤:** សមីការរាង: $a\sin^2 x+b\sin x\cos x+c\cos^2 x=d$

យើងដោះស្រាយសមីការនេះបានពីររបៀបខាងក្រោម:

✎ **វិធីដោះស្រាយទី១:** យើងគុណ $d$ និង $(\cos^2 x+\sin^2 x)$ ព្រោះ

$\cos^2 x+\sin^2 x=1$ នោះយើងបានសមីការការទៅជា:

$a\sin^2 x+b\sin x\cos x+c\cos^2 x=d\sin^2 x+d\cos^2 x$ យើងចែកអង្គទាំងពីរនិង $\cos^2 x$ ដែល $\cos x\neq 0$ នោះគេបាន:

$atg^2x+btgx+c=dtg^2x+d \Leftrightarrow (a-d)tg^2x+btgx+c-d=0$

យើងតាង: $t=tgx$ នោះសមីការខាងលើទៅជា:

$(a-d)t^2+bt+c-d=0$ ដោះស្រាយសមីការនេះដូច១៣ ។

**វិធីដោះស្រាយទី២:** យើងជំនួស

$\sin^2 x=\dfrac{1-\cos 2x}{2};\cos^2 x=\dfrac{1+\cos 2x}{2}$ ហើយ $\sin x\cos x=\dfrac{\sin 2x}{2}$

នោះសមីការខាងលើទៅជា: $b\sin 2x+(c-a)\cos 2x=2d-a-c$

$\Leftrightarrow (c-a)\cos 2x+b\sin 2x=2d-a-c$ ដោះស្រាយដូច១៣ ។

**វិធីសាស្ត្រទី១៥:** សមីការរាង: $a(\sin x+\cos x)+b\sin x\cos x+c=0$

**វិធីដោះស្រាយ:** យើងតាង: $y=\sin x+\cos x$ នោះគេបាន:

$\sin x\cos x=\dfrac{y^2-1}{2}$ ជំនួសចូលសមីការខាងលើយើងបាន:

$by^2+2ay+2c-b=0\ ;\left(|y|\le\sqrt{2}\right)$

**វិធីសាស្ត្រទី១៦:** សមីការរាង: $\begin{cases}\sin x=m\\ |m|\le 1\end{cases}$

**វិធីដោះស្រាយ:** ចំពោះសមីការនេះយើងទាញបាន:

$\Leftrightarrow\ x=(-1)^k\arcsin m+k\pi\ (k\in\mathbb{Z})$

**វិធីសាស្ត្រទី១៧:** សមីការរាង: $\begin{cases}\cos x=m\\ |m|\le 1\end{cases}$

**វិធីដោះស្រាយ:** ចំពោះសមីការនេះយើងទាញបាន:

$\Leftrightarrow\ x=\pm\arccos m+2k\pi\ (k\in\mathbb{Z})$

✳ **វិធីសាស្ត្រទី១៨:**សមីការរាង: $\begin{cases} tgx = m \\ m \in IR \end{cases}$

✍ **វិធីដោះស្រាយ:**ចំពោះសមីការនេះយើងទាញបាន:

$$\Leftrightarrow \ x = arctgm + k\pi \left(k \in IZ\right)$$

✳ **វិធីសាស្ត្រទី១៩:**សមីការរាង: $\begin{cases} \cot gx = m \\ m \in IR \end{cases}$

✍ **វិធីដោះស្រាយ:**ចំពោះសមីការនេះយើងទាញបាន:

$$\Leftrightarrow \ x = arc\cot gm + k\pi \left(k \in IZ\right)$$

## លក្ខណៈពិសេសមួយចំនួននៃសមីការ

✍ **លក្ខណៈទី១:**ពេលយើងឃើញមានសមីការ:

$A^2 + B^2 + C^2 = 0$ គេទាញបាន: $\begin{cases} A = 0 \\ B = 0 \\ C = 0 \end{cases}$

✍ **លក្ខណៈទី២:**បើ $\begin{cases} A = B \\ B \le m \\ B \ge m \end{cases} \Leftrightarrow \begin{cases} A = m \\ B = m \end{cases}$

✍ **លក្ខណៈទី៣:**បើ $\begin{cases} A.B = 1 \\ |A| \le 1 \\ |B| \le 1 \end{cases} \Leftrightarrow \begin{cases} A = 1 \\ B = 1 \end{cases} \vee \begin{cases} A = -1 \\ B = -1 \end{cases}$

✎ **លក្ខណៈទី៤:** បើ $\begin{cases} A+B=2 \\ |A|\le 1 \\ |B|\le 1 \end{cases} \Leftrightarrow \begin{cases} A=1 \\ B=1 \end{cases}$

✎ **លក្ខណៈទី៥:** បើ $\begin{cases} A+B=-2 \\ |A|\le 1 \\ |B|\le 1 \end{cases} \Leftrightarrow \begin{cases} A=-1 \\ B=-1 \end{cases}$

✎ **លក្ខណៈទី៦:** បើ $\begin{cases} A+B=A_1+B_1 \\ A\le A_1 \\ B\le B_1 \end{cases} \Leftrightarrow \begin{cases} A=A_1 \\ B=B_1 \end{cases}$

✳ **វិធីសាស្ត្រពិសេស:** មានសមីការនិងវិសមីការជាច្រើនដែលគេមិនអាចដោះស្រាយតាមវិធីសាស្ត្រដូចបានបង្ហាញខាងលើតែគេដោះស្រាយសមីការនិងវិសមីការទាំងនោះទៅនឹងលក្ខណៈនៃវិសមភាពមួយចំនួន ខ្ញុំសង្កេតឃើញមានវិសមភាពមួយ ចំនួនដែលតែងតែយកមកដោះស្រាយដូចជា:

១.**វិសមភាពកូស៊ី**(cauchy ):

យើងមាន: $a,b\ge 0 \Leftrightarrow \dfrac{a+b}{2}\ge\sqrt{ab}$

ជាទូទៅ:បើ $a_i\ge 0; i=1,2,...,n$ នោះគេបាន:

$$\frac{a_1+a_2+a_3+....+a_n}{n}\ge\sqrt[n]{a_1a_2a_3....a_n}$$

✎ **វិធីសាស្ត្រទី១:** យើងអាចយកវិសមភាពនេះទៅដោះស្រាយសមីការនិងវិសមីការមួយចំនួនដោយសង្កេតឃើញថាវិសមភាពនេះក្លាយជាសមភាពពេលដែល:

$$a=b;\ a_1=a_2=a_3=.....=a_n$$

**២.វិសមភាពប៊ូនីញ៉ាកូវស្គី**(Bunhiakouski):

យើងមាន: $\forall a_1, b_1, a_2, b_2 \in IR$ នោះយើងបាន:

$$(a_1b_1 + a_2b_2)^2 \le (a_1^2 + a_2^2)(b_1^2 + b_2^2)$$

ជាទូទៅ:បើ $a_i, b_i \in IR$ នោះគេបាន:

$$(a_1b_1 + a_2b_2 + \dots + a_nb_n)^2 \le (a_1^2 + a_2^2 + \dots + a_n^2)(b_1^2 + b_2^2 + \dots + b_n^2)$$

**វិធីសាស្ត្រទី២:** វិសមភាពនេះក្លាយជាសមភាពពេលដែល:

$$a_1b_2 = a_2b_2 \Leftrightarrow \frac{a_1}{b_1} = \frac{a_2}{b_2} \Leftrightarrow \frac{a_1}{b_1} = \frac{a_2}{b_2} = \frac{a_3}{b_3} = \dots = \frac{a_n}{b_n}$$ ។

**៣.វិសមភាពមីនកូវស្គី**(Minkouski):

យើងមាន: $\forall a_1, a_2, b_1, b_2 \in IR$ នោះយើងបាន:

$$\sqrt{(a_1 + b_1)^2 + (a_2 + b_2)^2} \le \sqrt{a_1^2 + b_1^2} + \sqrt{a_2^2 + b_2^2}$$

ជាទូទៅ: $\forall a_i, b_i \in IR$ នោះគេបាន:

$$\sqrt{(a_1 + a_2 + \dots + a_2)^2} + \sqrt{(b_1 + b_2 + \dots + b_n)^2} \le$$

$$\sqrt{a_1^2 + b_1^2} + \sqrt{a_2^2 + b_2^2} + \dots + \sqrt{a_n^2 + b_n^2}$$

**វិធីសាស្ត្រទី៣:** វិសមភាពនេះក្លាយជាសមភាពពេលដែល:

$$\frac{a_1}{b_1} = \frac{a_2}{b_2} = \dots = \frac{a_n}{b_n}$$

**៤.វិសមភាពប៊ែនូយី**(Bernoulli)

យើងមាន: $\forall x > -1, n \in IN^*$ នោះយើងបាន:

$$(1 + x)^n \ge 1 + nx$$

**វិធីសាស្ត្រទី៤:** វិសមភាពនេះក្លាយជាសមភាពពេលដែល: $x = 0 \vee n = 1$

# លំហាត់លើផ្នែកទី១

**លំហាត់ទី១:** ចូរដោះស្រាយសមីការខាងក្រោម:

$$1.\ x^4 + x^3 - 7x^2 - x + 6 = 0$$

$$2.\ x^4 - 4x - 1 = 0$$

***ដកស្រង់ចេញពីការប្រលងចូលមហាវិទ្យាល័យនិងមធ្យមសិក្សាក៏រិតពីរវៀតណាម***

## ចំលើយ

យើងមានសមីការ: $1.\ x^4 + x^3 - 7x^2 - x + 6 = 0$

$$\Leftrightarrow (x-1)(x^3 + 2x^2 - 5x - 6) = 0$$

$$\Leftrightarrow (x-1)(x-2)(x^2 + 4x + 3) = 0$$

$$\Leftrightarrow \left[\begin{array}{l} x = 1 \\ x = 2 \\ x^2 + 4x + 3 = 0 \end{array}\right. \quad \Leftrightarrow \left[\begin{array}{l} x = 1 \\ x = 2 \\ x = -1 \\ x = -3 \end{array}\right.$$

ដូចនេះសមីការមានរឹស: $x \in \{-3, -1, 1, 2\}$។

យើងមានសមីការ: $2.x^4 - 4x - 1 = 0$

$\Leftrightarrow x^4 + 2x^2 - 2x^2 - 4x - 2 + 1 = 0$

$\Leftrightarrow \left(x^2 + 1\right)^2 = 2\left(x + 1\right)^2$

$$\Leftrightarrow \left[\begin{array}{l} x^2 + 1 = \sqrt{2}\left(x + 1\right) \\ x^2 + 1 = -\sqrt{2}\left(x + 1\right) \end{array}\right. \Leftrightarrow \left[\begin{array}{l} x^2 - \sqrt{2}x + 1 - \sqrt{2} = 0 \ (1) \\ x^2 + \sqrt{2}x + 1 + \sqrt{2} = 0 \ (2) \end{array}\right.$$

+បើ: $x^2 - \sqrt{2}x + 1 - \sqrt{2} = 0 \Leftrightarrow \left[\begin{array}{l} x = \frac{1}{2}\left(\sqrt{2} - \sqrt{4\sqrt{2} - 2}\right) \\ x = \frac{1}{2}\left(\sqrt{2} + \sqrt{4\sqrt{2} - 2}\right) \end{array}\right.$

+បើ: $x^2 + \sqrt{2}x + 1 + \sqrt{2} = 0$ សមីការគ្មានឫសព្រោះ: $\Delta > 0$ ។

ដូចនេះសមីការមានឫស: $\left[\begin{array}{l} x = \frac{1}{2}\left(\sqrt{2} - \sqrt{4\sqrt{2} - 2}\right) \\ x = \frac{1}{2}\left(\sqrt{2} + \sqrt{4\sqrt{2} - 2}\right) \end{array}\right.$ ។

**លំហាត់ទី២:** ចូរដោះស្រាយសមីការខាងក្រោម:

$A. \sqrt{1 - x} = \sqrt{6 - x} - \sqrt{-5 - 2x}$

$B. \sqrt{x + 2\sqrt{x - 1}} + \sqrt{x - 2\sqrt{x - 1}} = \frac{x + 3}{2}$

***ដកស្រង់ចេញពីវិញ្ញាសាប្រឡងសិស្សពូកែវៀតណាម***

**ចំលើយ**

យើងមានសមីការ: $A. \sqrt{1 - x} = \sqrt{6 - x} - \sqrt{-5 - 2x}$

សមីការនេះមានន័យកាលណា: $\begin{cases} 1-x \geq 0 \\ 6-x \geq 0 \\ -5-2x \geq 0 \end{cases} \Leftrightarrow x \leq -\dfrac{5}{2}$

$$\Leftrightarrow \sqrt{1-x}+\sqrt{-5-2x}=\sqrt{6-x}$$

$$\Leftrightarrow 1-x+(-5-2x)+2\sqrt{(1-x)(-5-2x)}=6-x$$

$$\Leftrightarrow \sqrt{(1-x)(-5-2x)}=x+5$$

$$\Leftrightarrow \begin{cases} x \geq -5 \\ (1-x)(-5-2x)=(x+5)^2 \end{cases} \Leftrightarrow \begin{cases} x \geq -5 \\ x^2-7x-30=0 \end{cases}$$

$$\Leftrightarrow \begin{cases} x \geq -5 \\ \left[\begin{array}{l} x=-3 \\ x=10 \end{array}\right. \end{cases} \Leftrightarrow \left[\begin{array}{l} x=-3 \\ x=10 \end{array}\right.$$

ដោយ $x \leq -\dfrac{5}{2}$ នោះយើងបានរឹសសមីការគឺ: $x=-3$ ។

យើងមានសមីការ: $B.\sqrt{x+2\sqrt{x-1}}+\sqrt{x-2\sqrt{x-1}}=\dfrac{x+3}{2}$

សមីការមានន័យកាលណា:

$$\begin{cases} x \geq 1 \\ x-2\sqrt{x-1} \geq 0 \end{cases} \Leftrightarrow \begin{cases} x \geq 1 \\ x \geq 2\sqrt{x-1} \end{cases} \Leftrightarrow \begin{cases} x \geq 1 \\ x^2 \geq 4(x-1) \end{cases}$$

$$\Leftrightarrow \begin{cases} x \geq 1 \\ (x-2)^2 \geq 0 \end{cases} \Leftrightarrow x \geq 1$$

ដូចនេះសមីការខាងលើ:

$$\Leftrightarrow \sqrt{x-1+2\sqrt{x-1}+1}+\sqrt{x-1-2\sqrt{x-1}+1}=\frac{x+3}{2}$$

$$\Leftrightarrow \sqrt{\left(\sqrt{x-1}+1\right)^2}+\sqrt{\left(\sqrt{x-1}-1\right)^2}=\frac{x+3}{2}$$

$$\Leftrightarrow \left|\sqrt{x-1}+1\right|+\left|\sqrt{x-1}-1\right|=\frac{x+3}{2}$$

+ចំពោះ: $\sqrt{x-1}-1\ge 0 \Leftrightarrow x\ge 2$ នោះគេបាន:

$$2\sqrt{x-1}=\frac{x+3}{2}\Leftrightarrow 4(x-1)=\left(\frac{x+3}{2}\right)^2$$

$$\Leftrightarrow x^2-10x+25=0\Leftrightarrow x=5$$

+ចំពោះ: $1\le x\le 2$ នោះគេបាន: $\frac{x+3}{2}=2\Leftrightarrow x=1$

ដូចនេះសមីការមានឫស: $x=1 \vee x=5$ ។

"មនុស្សឆ្លាត គេគិតមុនគេ"

**លំហាត់ទី៣:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x+\sqrt{x^2+16}=\dfrac{40}{\sqrt{x^2+16}}$

$B.\ \sqrt[3]{x+1}+\sqrt[3]{3x+1}=\sqrt[3]{x-1}$

$C.\ \sqrt{77-x^2+x\sqrt{x+5}}=\sqrt{3-2x-x^2}$

***ដកស្រង់ចេញពីការប្រលងចូលមធ្យមសិក្សាកំរិតពីរវៀតណាម១៩៧០***

***និងប្រលងចូលមហាវិទ្យាល័យផ្នែកអគ្គិសនី***

**ចំលើយ**

យើងមានសមីការៈ $A.\ x+\sqrt{x^2+16}=\dfrac{40}{\sqrt{x^2+16}}$

$$\Leftrightarrow\ x\sqrt{x^2+16}+x^2+16=40$$

$$\Leftrightarrow\ x\sqrt{x^2+16}=24-x^2$$

$$\Rightarrow\ x^2\left(x^2+16\right)=\left(24-x^2\right)^2$$

$$\Leftrightarrow\ 64x^2=576\Leftrightarrow\ x=\pm 3$$

ដោះពេល $x=-3$ សមីការមិនផ្ទៀងផ្ទាត់នោះសមីការមានរឹសតែៈ $x=3$ ។

យើងមានសមីការៈ $B.\ \sqrt[3]{x+1}+\sqrt[3]{3x+1}=\sqrt[3]{x-1}$

$$\Leftrightarrow\ \left(\sqrt{x+1}+\sqrt{3x+1}\right)^3=x-1$$

$$\Leftrightarrow\ 4x+2+\sqrt[3]{x+1}\sqrt[3]{3x+1}\left(\sqrt[3]{x+1}+\sqrt[3]{3x+1}\right)=x-1$$

$$\Leftrightarrow\ 4x+2+3\sqrt[3]{x+1}\sqrt[3]{3x+1}\sqrt[3]{x-1}=x-1$$

$$\Leftrightarrow\ \sqrt[3]{x+1}\sqrt[3]{3x+1}\sqrt[3]{x-1}=-(x+1)$$

$$\Leftrightarrow\ (x+1)(3x+1)(x-1)=-(x+1)^3$$

$$\Leftrightarrow\ (x+1)\left[(x-1)(3x+1)+(x+1)^2\right]=0$$

$$\Leftrightarrow\ (x+1)\left(4x^2\right)=0\Leftrightarrow\ \begin{cases}x=-1\\x=0\end{cases}$$

ដោយៈ $x=0$ មិនផ្ទៀងផ្ទាត់សមីការនោះសមីការមានរឹសៈ $x=-1$ ។

យើងមានសមីការៈ $C.\sqrt{77-x^2+x\sqrt{x+5}}=\sqrt{3-2x-x^2}$

សមីការមានន័យកាលណាៈ $3-2x-x^2\geq 0\Leftrightarrow -3\leq x\leq 1$

$\Leftrightarrow\ x\sqrt{x+5}=-4-2x$

$\Rightarrow\ x^2(x+5)=(4+2x)^2$

$\Leftrightarrow\ x^3+x^2-16x-16=0$

$\Leftrightarrow\ (x+1)(x^2-16)=0 \Leftrightarrow \left[\begin{array}{l} x=-1 \\ x=\pm 4 \text{ មិនយក} \end{array}\right.$

ដូចនេះសមីការមានឫស: $x=-1$ ។

> **លំហាត់ទី៤:** ចូរដោះស្រាយសមីការខាងក្រោម:
>
> $A.\ 1-\sqrt{x-\sqrt{x+8}}=\sqrt{x+1}$
>
> $B.\ \sqrt[3]{x+34}-\sqrt[3]{x-3}=1$
>
> ***ដកស្រង់ចេញពីការប្រលងប្រជែងនៅប្រទេសអ៊ុយក្រែន***

## ចំលើយ

យើងមានសមីការ: $A.\ 1-\sqrt{x-\sqrt{x+8}}=\sqrt{x+1}$

សមីការនេះមានន័យកាលណា:

$$\begin{cases} x\ge -1 \\ x\ge\sqrt{x+8} \end{cases} \Leftrightarrow \begin{cases} x\ge -1 \\ x^2-x-8\ge 0 \end{cases} \Leftrightarrow \begin{cases} x\ge 0 \\ \left[\begin{array}{l} x\le \dfrac{1-\sqrt{33}}{2} \\ x\ge \dfrac{1+\sqrt{33}}{2} \end{array}\right. \end{cases} \Leftrightarrow x\ge\frac{1+\sqrt{33}}{2}$$

នោះសមីការ: $\Leftrightarrow \sqrt{x-\sqrt{x+8}}=\sqrt{x+1}-1$

$$\Leftrightarrow x-\sqrt{x+8}=x+2-2\sqrt{x+1}$$
$$\Leftrightarrow 2\sqrt{x+1}=2+\sqrt{x+8}$$
$$\Leftrightarrow 4(x+1)=4+x+8+4\sqrt{x+8}$$
$$\Leftrightarrow 4\sqrt{x+8}=3x-8 \Leftrightarrow 16(x+8)=9x^2-48x+64$$
$$\Leftrightarrow 9x^2-64x-64=0 \Leftrightarrow \begin{cases} x=-\frac{8}{9} \text{ មិនយក} \\ x=8 \text{ យក} \end{cases}$$

ដូចនេះសមីការមានឫស: $x=8$ ។

យើងមានសមីការ: $B.\ \sqrt[3]{x+34}-\sqrt[3]{x-3}=1$

$$\Leftrightarrow x+34-x+3=3\sqrt[3]{x+34}.\sqrt[3]{x-3}\left(\sqrt[3]{x+34}+\sqrt[3]{x-3}\right)=1$$
$$\Leftrightarrow \sqrt[3]{x+34}.\sqrt[3]{x-3}=12$$
$$\Leftrightarrow (x+34)(x-3)=12^3$$
$$\Rightarrow x^2+31x-1830=0$$
$$\Leftrightarrow \begin{cases} x=30 \\ x=-16 \end{cases}$$

ដូចនេះសមីការមានឫស: $x=30 \vee x=-61$ ។

**លំហាត់ទី៥:** ចូរដោះស្រាយសមីការខាងក្រោម:

$$A.\ \frac{x^2-4x+4}{x-1}+\frac{x^2-3x-1}{x-2}=\frac{2\left(x^2-5x+5\right)}{x-3}$$
$$B.\ \sqrt[3]{2x-1}+\sqrt[3]{2x+1}=\sqrt[3]{10x}$$

***ដកស្រង់ចេញពីវិញ្ញាសាត្រៀមប្រលងសិស្សពូកែ១៩៧៨***

## ចំលើយ

យើងមានសមីការ: $A.\dfrac{x^2-4x+4}{x-1}+\dfrac{x^2-3x-1}{x-2}=\dfrac{2\left(x^2-5x+5\right)}{x-3}$

សមីការនេះមានន័យកាលណា: $\begin{cases} x-1\neq 0 \\ x-2\neq 0 \\ x-3\neq 0 \end{cases} \Leftrightarrow \begin{cases} x\neq 1 \\ x\neq 2 \\ x\neq 3 \end{cases}$

នោះយើងបានសមីការខាងលើ:

$$\Leftrightarrow \frac{\left(x^2-4x+4\right)\left(x-2\right)+\left(x^2-3x-1\right)\left(x-1\right)}{\left(x-1\right)\left(x-2\right)}=\frac{2\left(x^2-5x+5\right)}{x-3}$$

$$\Leftrightarrow \frac{\left(x^3-6x^2+12x-8\right)+\left(x^3-4x^2+2x+1\right)}{x^2-3x+2}=\frac{2\left(x^2-5x+5\right)}{x-3}$$

$$\Leftrightarrow \frac{2x^3-10x^2+14x-7}{x^2-3x+2}=\frac{2\left(x^2-5x+5\right)}{x-3}$$

$$\Leftrightarrow \left(2x^3-10x^2+14x-7\right)\left(x-3\right)=2\left(x^2-5x+5\right)\left(x^2-3x+2\right)$$

$$\Leftrightarrow 2x^4-16x^3+44x^2-49x+21=2x^4-16x^3+44x^2-50x+20$$

$$\Leftrightarrow x=-1$$

ដូចនេះសមីការមានរឹស: $x=-1$ ។

យើងមានសមីការ: $B.\sqrt[3]{2x-1}+\sqrt[3]{2x+1}=\sqrt[3]{10x}$

$$\Leftrightarrow 2x-1+2x+1+3\sqrt[3]{2x-1}\sqrt[3]{2x+1}\left(\sqrt[3]{2x-1}+\sqrt[3]{2x+1}\right)=10x$$

$$\Rightarrow \sqrt[3]{2x-1}\sqrt[3]{2x+1}\sqrt[3]{10x}=2x$$

$$\Leftrightarrow 2x-1+2x+1+3\sqrt[3]{2x-1}\sqrt[3]{2x+1}\left(\sqrt[3]{2x-1}+\sqrt[3]{2x+1}\right)=10x$$

$$\Rightarrow \sqrt[3]{2x-1}\sqrt[3]{2x+1}\sqrt[3]{10x}=2x$$

$$\Rightarrow (2x-1)(2x+1)10x=8x^3$$

$$\Leftrightarrow x\left[5(2x-1)(2x+1)-4x^2\right]=0$$

$$\Rightarrow x\left(16x^2-5\right)=0 \Rightarrow \left[\begin{array}{l} x=0 \\ x=\dfrac{\sqrt{5}}{4} \\ x=-\dfrac{\sqrt{5}}{4} \end{array}\right.$$

ដូចនេះសមីការមានឫស: $x=0; x=\pm\dfrac{\sqrt{5}}{4}$ ។

**លំហាត់ទី៦:** ចូរដោះស្រាយសមីការខាងក្រោម:

$$A.\ \frac{x^2-4x+5}{x^2+6x+10}=\left(\frac{x-2}{x+3}\right)^2$$

$$B.\ \frac{\dfrac{1+x}{1-x}-\dfrac{1-x}{1+x}}{\dfrac{1-x}{1-x}-1}=\frac{3}{14-x}$$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងសិស្សពូកែ១៩៧៧***

**ចំលើយ**

យើងមានសមីការ: $A.\ \dfrac{x^2-4x+5}{x^2+6x+10}=\left(\dfrac{x-2}{x+3}\right)^2$

យើងមាន: $x^2+6x+10=(x+3)^2+1\neq 0\quad \forall x$ និង

$(x+3)\neq 0\Leftrightarrow x\neq -3$ នោះដើម្បីអោយសមីការមានន័យលុះត្រាតែ $x\neq -3$

យើងមាន: $\dfrac{x^2-4x+5}{x^2+6x+10}=\left(\dfrac{x-2}{x+3}\right)^2$

$$\Leftrightarrow \frac{x^2-4x+5}{x^2+6x+10}=\frac{x^2-4x+4}{x^2+6x+9}=1$$

$$\Leftrightarrow x^2-4x+5=x^2+6x+10$$

$$\Leftrightarrow 10x=-5$$

$$\Leftrightarrow x=-\frac{1}{2}$$

ដូចនេះសមីការមានរឹស: $x=-\dfrac{1}{2}$ ។

យើងមានសមីការ: $B.\dfrac{\dfrac{1+x}{1-x}-\dfrac{1-x}{1+x}}{\dfrac{1-x}{1-x}-1}=\dfrac{3}{14-x}$

សមីការនេះមានន័យកាលណា: $\begin{cases}1-x\neq 0\\ 1+x\neq 0\\ 1+x\neq 1-x\\ 14-x\neq 0\end{cases}\Leftrightarrow\begin{cases}x\neq 1\\ x\neq -1\\ x\neq 0\\ x\neq 14\end{cases}$

នោះយើងបានសមីការ: $B.\dfrac{\dfrac{1+x}{1-x}-\dfrac{1-x}{1+x}}{\dfrac{1-x}{1-x}-1}=\dfrac{3}{14-x}$

$$\Leftrightarrow \frac{(1+x)^2-(1-x)^2}{(1+x)^2-(1-x^2)}=\frac{3}{14-x}$$

$$\Leftrightarrow \frac{4x}{2x(14-x)}=\frac{3}{14-x}$$

$$\Leftrightarrow 2(14-x)=3(x+1)$$

$$\Leftrightarrow 5x=25$$

$$\Rightarrow x=5$$

ដូចនេះសមីការមានឫស: $x=5$ ។

*"អវិជ្ជាជាគ្រឿងដែលនាំអោយមនុស្សគិតមិនសូវបានត្រឹមត្រូវ និងប្រព្រឹត្តអំពើអាក្រក់"*

**លំហាត់ទី៧:** ចូរដោះស្រាយសមីការខាងក្រោម

$$\frac{\frac{1}{1+x}}{1-\frac{1}{1+x}}+\frac{\frac{1}{1+x}}{\frac{x}{1-x}}+\frac{\frac{1}{1-x}}{\frac{x}{1+x}}+\frac{3}{2x}=0$$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងសិស្សពូកែវៀតណាម១៩៨១***

**ចំលើយ**

យើងមានសមីការ: $$\frac{\frac{1}{1+x}}{1-\frac{1}{1+x}}+\frac{\frac{1}{1+x}}{\frac{x}{1-x}}+\frac{\frac{1}{1-x}}{\frac{x}{1+x}}+\frac{3}{2x}=0$$

សមីការមានន័យកាលណា: $$\begin{cases}1+x\neq 0\\1-x\neq 0\\x\neq 0\end{cases}\Leftrightarrow\begin{cases}x\neq -1\\x\neq 1\\x\neq 0\end{cases}$$

នោះសមីការ: $$\frac{\frac{1}{1+x}}{1-\frac{1}{1+x}}+\frac{\frac{1}{1+x}}{\frac{x}{1-x}}+\frac{\frac{1}{1-x}}{\frac{x}{1+x}}+\frac{3}{2x}=0$$

$$\Leftrightarrow \frac{1}{x}+\frac{1-x}{x(1+x)}+\frac{1+x}{x(1-x)}+\frac{3}{2x}=0$$

$$\Leftrightarrow 5\left(1-x^2\right)+2(1-x)^2+2(1+x)^2=0$$

$$\Leftrightarrow x^2-9=0$$

$$\Leftrightarrow (x-3)(x+3)=0$$

$$\Rightarrow \left[\begin{array}{l}x-3=0\\x+3=0\end{array}\right.\Leftrightarrow\left[\begin{array}{l}x=3\\x=-3\end{array}\right.$$

ដូចនេះសមីការមានរឹស: $x=-3$ ; $x=3$ ។

" មនុស្សជោគជ័យគេមិនដែលបោះបង់"

**លំហាត់ទី៨:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\sqrt{x^2-3x+3}+\sqrt{x^2-3x+6}=3$

$B.\sqrt{x^2+x+7}+\sqrt{x^2+x+2}=\sqrt{3x^2+3x+19}$

***ដកស្រង់ចេញពីវិញ្ញាសាត្រៀមប្រលងចូលមហាវិទ្យាល័យ១៩៨៤***

## ចំលើយ

យើងមានសមីការ: $A.\sqrt{x^2-3x+3}+\sqrt{x^2-3x+6}=3$

យើងតាង: $t=x^2-3x+3=\left(x-\frac{3}{2}\right)^2+\frac{3}{4}\geq\frac{3}{4}\Rightarrow t\geq\frac{3}{4}$

$$\sqrt{t}+\sqrt{t+3}=3$$

$$\Leftrightarrow 2t+3+2\sqrt{t^2+3t}=9$$

នោះសមីការទៅជា: $\Leftrightarrow \sqrt{t^2+3t}=3-t$

$$\Leftrightarrow\begin{cases}3-t\geq 0\\ t^2+3t=(3-t)^2\end{cases}\Leftrightarrow\begin{cases}\frac{3}{4}\leq t\leq 3\\ t=1\end{cases}\Leftrightarrow t=1$$

+បើ $t=1$ នោះគេបាន: $x^2-3x+3=1\Leftrightarrow x^2-3x+2=0\Leftrightarrow\left[\begin{array}{l}x=1\\ x=2\end{array}\right.$

ដូចនេះសមីករមានរឹស: $x=1;\ x=2$ ។

យើងមានសមីការ: $B.\sqrt{x^2+x+7}+\sqrt{x^2+x+2}=\sqrt{3x^2+3x+19}$

យើងតាង: $t=x^2+x+2=\left(x+\frac{1}{2}\right)^2+\frac{7}{4}\geq\frac{7}{4}\Rightarrow t\geq\frac{7}{4}$

នោះសមីការទៅជា: $\sqrt{t+5}+\sqrt{t}=\sqrt{3t+13}$

$$\Leftrightarrow 2t+5+2\sqrt{t(t+5)}=3t+13$$

$$\Leftrightarrow 2\sqrt{t(t+5)}=t+8$$

$$\Leftrightarrow 4t(t+5)=(1+8)^2$$

$$\Leftrightarrow 3t^2+4t-64=0 \Leftrightarrow \left[\begin{array}{l} t=-\frac{16}{3} \\ t=4 \end{array}\right.$$

+ចំពោះ $t=-\frac{16}{3}$ មិនយក

+ចំពោះ $t=4 \Leftrightarrow x^2+x+2=4 \Leftrightarrow x^2+x-2=0 \Rightarrow \left[\begin{array}{l} x=1 \\ x=-2 \end{array}\right.$

ដូចនេះសមីការមានរឹស: $x=-2; x=1$ ។

**លំហាត់ទី៨:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ 1-\sqrt{x+\sqrt{x+1}+1}=\sqrt{x+1}$

$B.\ \sqrt{4x^2+5x+1}+2\sqrt{x^2-x+1}=9x-3$

$C.\ x+\sqrt{17-x^2}+x\sqrt{17-x^2}=9$

***ដកស្រង់ចេញពីការប្រលងចូលមហាវិទ្យាល័យkolomen***

## ចំលើយ

យើងមានសមីការ: $A.\ 1-\sqrt{x+\sqrt{x+1}+1}=\sqrt{x+1}$

សមីការនេះមានន័យកាលណា: $x+1\geq 0 \Rightarrow x\geq -1$

យើងតាង: $t=\sqrt{x+1}\geq 0 \Rightarrow t^2=x+1$ នោះសមីការខាងលើទៅជា:

$$1-\sqrt{t^2+t}=t \Leftrightarrow \sqrt{t^2+t}=1-t \Leftrightarrow \begin{cases} 0\le t\le 1 \\ t^2+t=(t-1)^2 \end{cases}$$

$$\Leftrightarrow \begin{cases} 0\le t\le 1 \\ t=\frac{1}{3} \end{cases} \Leftrightarrow t=\frac{1}{3}$$

+បើ $t=\frac{1}{3} \Leftrightarrow x+1=\frac{1}{9} \Leftrightarrow x=-\frac{8}{9}$

ដូចនេះសមីការមានរឹស: $x=-\frac{8}{9}$ ។

យើងមានសមីការ: $B.\sqrt{4x^2+5x+1}+2\sqrt{x^2-x+1}=9x-3$

សមីការមានន័យកាលណា: $\begin{cases} 4x^2+5x+1\ge 0 \\ 9x-3\ge 0 \end{cases} \Leftrightarrow \begin{cases} \left[\begin{array}{l} x\le -1 \\ x\ge -\frac{1}{4} \end{array}\right. \\ x\ge \frac{1}{3} \end{cases} \Leftrightarrow x\ge \frac{1}{3}$

យើងតាង: $\begin{cases} a=\sqrt{4x^2+5x+1}\ge 0 \\ b=2\sqrt{x^2-x+1}>0 \end{cases} \Rightarrow \begin{cases} a^2=4x^2+5x+1 \\ b^2=4x^2-4x+4 \end{cases}$

$$\Rightarrow a^2-b^2=9x-3$$

នោះសមីការខាងលើទៅជា: $a+b=a^2-b^2$

$\Leftrightarrow (a+b)(a-b-1)=0 \Leftrightarrow \left[\begin{array}{l} a+b=0 \\ a-b=1 \end{array}\right.$

+ករណី $a+b=0$ មិនយកព្រោះ $a\ge 0$ និង $b>0$

+ករណី $a-b=1 \Leftrightarrow a=b+1$

$$\Leftrightarrow \sqrt{4x^2+5x+1}=2\sqrt{x^2-x+1}+1$$

$$\Leftrightarrow 4x^2+5x+1=4x^2-4x+4+1+4\sqrt{x^2-x+1}$$

$$\Leftrightarrow 4\sqrt{x^2-x+1}=9x-4$$

$$\Leftrightarrow \begin{cases} x\geq \dfrac{4}{9} \\ 16\left(x^2-x+1\right)=81x^2-72x+16 \end{cases}$$

$$\Leftrightarrow \begin{cases} x\geq \dfrac{4}{9} \\ 65x^2-56x=0 \end{cases} \Leftrightarrow x=\frac{56}{65}$$

ដូចនេះគេបានសមីការមានឫស: $x=\dfrac{56}{65}$ ។

យើងមានសមីការ: $C.\ x+\sqrt{17-x^2}+x\sqrt{17-x^2}=9$

សមីការនេះមានន័យកាលណា: $17-x^2\geq 0\Rightarrow |x|\leq 17$

យើងតាង: $t=x+\sqrt{17-x^2}\Rightarrow |t|=\left|x+\sqrt{17-x^2}\right|\leq \sqrt{34}$

$\Rightarrow t^2=17+2x\sqrt{17-x^2}$ នោះសមីការទៅជា: $t+\dfrac{t^2-17}{2}=9$

$$\Leftrightarrow t^2+2t-35=0\Leftrightarrow \left[\begin{array}{l} t=-7 \text{ មិនយក} \\ t=5 \end{array}\right.$$

+បើ $t=5\Rightarrow x+\sqrt{17-x^2}=5\Leftrightarrow \sqrt{17-x^2}=5-x$

$$\Leftrightarrow \left[\begin{array}{l} 5-x\geq 0 \\ 17-x^2=(5-x)^2 \end{array}\right. \Leftrightarrow 2x^2-10x+8=0\Leftrightarrow \left[\begin{array}{l} x=1 \\ x=4 \end{array}\right.$$

ដូចនេះសមីការមានឫស: $x=1; x=4$ ។

"តក់ៗដូចទឹកភ្លោត ព្រឹកឡើងសោតពេញបំពង់ បានមកទុកអោយគង់ កុំអោយបង់បាត់ឡើយណា"ៗ

**លំហាត់ទី៩:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\sqrt{x-4\sqrt{x-4}}+\sqrt{x+4\sqrt{x-4}}=x$

$B.(4x-1)\left(\sqrt{x^2+1}\right)=2x^2+2x+1$

$C.\sqrt{3+x^2}+\sqrt{6-x^2}=3+\sqrt{\left(3+x^2\right)\left(6-x^2\right)}$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងចូលមហាវិទ្យាល័យ១៩៨៦***

## ចំលើយ

យើងមានសមីការ: $A.\sqrt{x-4\sqrt{x-4}}+\sqrt{x+4\sqrt{x-4}}=x$

សមីការនេះមានន័យកាលណា: $x-4\geq 0\Rightarrow x\geq 4$

យើងតាង: $t=\sqrt{x-4}\Rightarrow t^2=x-4\Rightarrow x=t^2+4$ នោះសមីការទៅជា:

$$\sqrt{t^2+4-4t}+\sqrt{t^2+4+4t}=t^2+4$$

$$\Leftrightarrow \sqrt{(t-2)^2}+\sqrt{(t+2)^2}=t^2+4$$

$$\Leftrightarrow |t-2|+t+2=t^2+4\ (*)$$

+បើ $t-2\geq 0\Leftrightarrow t\geq 2$ នោះ $(*)$ ទៅជា: $2t=t^2+4$ គ្មានឫស

+បើ $0\leq t\leq 2$ នោះ $(*)$ ទៅជា: $t^2+4=4\Leftrightarrow t=0\Rightarrow x=4$

ដូចនេះសមីការមានឫស: $x=4$ ។

យើងមានសមីការ: $B.(4x-1)\left(\sqrt{x^2+1}\right)=2x^2+2x+1$

យើងតាង: $t=\sqrt{x^2+1};t\geq 1$ នោះសមីការខាងលើទៅជា:

$$(4x-1)\sqrt{x^2+1}=2\left(x^2+1\right)+2x-1$$

$$\Rightarrow (4x-1)t=2t^2+2x-1$$

$$\Leftrightarrow 2t^2+(1-4x)t+2x-1=0$$

$$\Delta=(1-4x)^2-8(2x-1)=16x^2-24x+9=(4x-3)^2$$

$$\Rightarrow \left[\begin{array}{l} t=\frac{1}{4}(4x-1-4x+3)=\frac{1}{2} \text{ មិនយក} \\ t=\frac{1}{4}(4x-1+4x-3)=2x-1 \end{array}\right.$$

+បើ $t=2x-1$ នោះគេបាន:

$$\sqrt{x^2+1}=2x-1\Leftrightarrow\begin{cases}2x-1\geq 1\\ x^2+1=(2x-1)^2=4x^2-4x+1\end{cases}$$

$$\Leftrightarrow\begin{cases}x\geq 1\\ 3x^2-4x=0\end{cases}\Rightarrow x=\frac{4}{3}$$

ដូចនេះគេបានសមីការមានរឹស: $x=\frac{4}{3}$ ។

យើងមានសមីការ: $C.\sqrt{3+x^2}+\sqrt{6-x^2}=3+\sqrt{\left(3+x^2\right)\left(6-x^2\right)}$

សមីការនេះមានន័យកាលណា: $-\sqrt{6}\leq x\leq\sqrt{6}$

យើងតាង: $t=\sqrt{3+x^2}+\sqrt{6-x^2}>0$

$$\Rightarrow t^2=9+2\sqrt{\left(3+x^2\right)\left(6-x^2\right)}$$

$$\Rightarrow \sqrt{\left(3+x^2\right)\left(6-x^2\right)}=\frac{t^2-9}{2}$$

នោះសមីការខាងលើទៅជា:

$$t = 3 + \frac{t^2 - 9}{2} \Leftrightarrow t^2 - 2t - 3 = 0 \Rightarrow \left[\begin{array}{l} t = -1 \text{ មិនយក} \\ t = 3 \end{array}\right.$$

+បើ $t = 3$ នោះគេបាន: $\sqrt{3 + x^2 + \sqrt{6 - x^2}} = 3 \Leftrightarrow 9 + 2\sqrt{(3 + x^2)(6 - x^2)} = 9$

$$\Leftrightarrow x = \pm\sqrt{6}$$

ដូចនេះសមីការនេះមានរឹស: $x = \pm\sqrt{6}$ ។

**លំហាត់ទី១០:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x^2 + 3 - \sqrt{2x^2 - 3x + 2} = \frac{3}{2}x + 6$

$B.\ 2x - 5 + 2\sqrt{x^2 - 5x} + 2\sqrt{x - 5} + 2\sqrt{x} = 48$

$C.\ 2(x^2 - 3x + 2) = 3\sqrt{x^3 + 8}$

***ដកស្រង់ចេញពីវិញ្ញាសារត្រៀមចូលមហាវិទ្យាល័យវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ x^2 + 3 - \sqrt{2x^2 - 3x + 2} = \frac{3}{2}x + 6$

$$\Leftrightarrow 2x^2 - 3x + 2 - 2\sqrt{2x^2 - 3x + 2} - 8 = 0$$

យើងតាង: $t = \sqrt{2x^2 - 3x + 2};\ t > 0$ នោះសមីការខាងលើទៅជា:

$$\Leftrightarrow t^2 - 2t - 8 = 0 \Leftrightarrow \left[\begin{array}{l} t = -2 \text{ មិនយក} \\ t = 4 \end{array}\right.$$

+បើ $t=4$ នោះយើងបាន:

$$\sqrt{2x^2-3x+2}=4 \Leftrightarrow 2x^2-3x-14=0 \Rightarrow \left[\begin{array}{l} x=-2 \\ x=\dfrac{7}{2} \end{array}\right.$$

ដូចនេះសមីការមានរឹស: $x=-2 \vee x=\dfrac{7}{2}$ ។

យើងមានសមីការ: $B.\ 2x-5+2\sqrt{x^2-5x}+2\sqrt{x-5}+2\sqrt{x}=48$

សមីការនេះមានន័យកាលណា: $x-5\geq 0 \Rightarrow x\geq 5$

យើងតាង: $t=\sqrt{x-5}+\sqrt{x};t>0$ នោះគេបាន:

$t^2=2x-5+2\sqrt{x^2-5x}$ នោះសមីការខាងលើទៅជា:

$$t^2+2t-48=0 \Rightarrow \left[\begin{array}{l} t=-8 \quad \text{មិនយក} \\ t=6 \end{array}\right.$$

+បើ $t=6 \Leftrightarrow \sqrt{x-5}+\sqrt{x}=6$

$$\Leftrightarrow 2x-5+2\sqrt{x^2-5x}=36 \Leftrightarrow 2\sqrt{x^2-5x}=41-2x$$

$$\Leftrightarrow \begin{cases} 5\leq x\leq \dfrac{41}{2} \\ x=\dfrac{41^2}{144} \end{cases} \Leftrightarrow x=\left(\dfrac{41}{12}\right)^2$$

ដូចនេះសមីការមានរឹស: $x=\left(\dfrac{41}{12}\right)^2$ ។

យើងមានសមីការ: $C.2\left(x^2-3x+2\right)=3\sqrt{x^3+8}$

សមីការនេះមានន័យកាលណា:

$$\begin{cases} x^3+8\ge 0 \\ x^2-3x+2\ge 0 \end{cases} \Leftrightarrow \begin{cases} x\ge -2 \\ \left[\begin{array}{l} x\le 1 \\ x\ge 2 \end{array}\right. \end{cases} \Leftrightarrow \left[\begin{array}{l} -2\le x\le 1 \\ x\ge 2 \end{array}\right.$$

នោះសមីការខាងលើទៅជា: $2\left(2x^2-3x+2\right)=3\sqrt{\left(x+2\right)\left(x^2-2x+4\right)}$

យើងតាង: $\begin{cases} a=x+2 \\ b=x^2-2x+4 \end{cases} \Rightarrow b-a=x^2-3x+2$

នោះសមីការខាងលើទៅជា: $2\left(b-a\right)=3\sqrt{ab}$

$$\Leftrightarrow \begin{cases} b\ge a \\ 4\left(b-a\right)^2=9ab \end{cases} \Leftrightarrow \begin{cases} b\ge a \\ 4a^2+4b^2-17ab=0 \end{cases}$$

$$\Leftrightarrow 4a^2-17a+4b^2=0 \Leftrightarrow \left[\begin{array}{l} a=\dfrac{b}{4} \\ a=4b \end{array}\right.$$

នោះគេបាន: $a=\dfrac{b}{4} \Leftrightarrow 4a=b$

$$\Leftrightarrow 4\left(x+2\right)=x^2-2x+4$$

$$\Leftrightarrow x^2-6x-4=0$$

$$\Leftrightarrow \left[\begin{array}{l} x=3-\sqrt{13} \\ x=3+\sqrt{13} \end{array}\right.$$

ដូចនេះសមីការមានឫស: $x=3\pm\sqrt{13}$ ។

"មនុស្សឆ្លាតចេះសម្លឹងទៅមុខ"ៗ

**លំហាត់ទី១១:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x^2-3x-5\sqrt{9x^2+x-2}=\frac{11}{4}-\frac{28}{9}x$

$B.\ x-4=\frac{x^2}{\left(\sqrt{1+x}+1\right)^2}$

$C.\ \sqrt{x-1}+\sqrt{x+3}+2\sqrt{(x-1)(x+3)}=4-2x$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងចូលមហាវិទ្យាល័យវៀតណាម***

យើងមានសមីការ: $A.\ x^2-3x-5\sqrt{9x^2+x-2}=\frac{11}{4}-\frac{28}{9}x$

សមីការនេះមានន័យកាលណា: $9x^2+x-2\ge 0 \Leftrightarrow \left[\begin{array}{l} x\le \frac{-1-\sqrt{73}}{18} \\ x\ge \frac{-1+\sqrt{73}}{18}\end{array}\right.$

នោះសមីការខាងលើទៅជា: $\frac{9x^2+x-2}{9}-5\sqrt{9x^2+x-2}-\frac{91}{36}=0$

យើងតាង: $t=\sqrt{9x^2+x-2}; t>0 \Rightarrow t^2=9x^2+x-2$

នោះសមីការខាងលើទៅជា: $\frac{t^2}{9}-5t-\frac{91}{36}=0 \Leftrightarrow 4t^2-180t-91=0$

$\Leftrightarrow \left[\begin{array}{l} t=-\frac{1}{2} \text{ មិនយក} \\ t=\frac{91}{2}\end{array}\right.$

$t=\frac{91}{2}\Leftrightarrow\sqrt{9x^2+x-2}=\frac{91}{2}$

+បើ $\Leftrightarrow 9x^2+x-2=\frac{91^2}{4}\Leftrightarrow 36x^2+4x-8289=0$

$$\Leftrightarrow\left[\begin{array}{l}x=\frac{-2-\sqrt{298408}}{36}\\ x=\frac{-2+\sqrt{298408}}{36}\end{array}\right.$$

ដូចនេះសមីការមានរឹស: $x=\frac{-2\pm\sqrt{298408}}{36}$ ។

យើងមានសមីការ: $B.\ x-4=\frac{x^2}{\left(\sqrt{1+x}+1\right)^2}$

សមីការនេះមានន័យកាលណា: $x\geq 4$

នោះគេបាន: $x-4=\frac{x^2\left(\sqrt{1+x}-1\right)^2}{\left[\left(\sqrt{1+x}+1\right)\left(\sqrt{1+x}-1\right)\right]^2}$

$$\Leftrightarrow x-4=\left(\sqrt{1+x}-1\right)^2=2+x-2\sqrt{1+x}$$

$$\Leftrightarrow \sqrt{1+x}=3\Rightarrow x=8$$

ដូចនេះសមីការនេះមានរឹស: $x=8$ ។

យើងមានសមីការ: $C.\ \sqrt{x-1}+\sqrt{x+3}+2\sqrt{(x-1)(x+3)}=4-2x$

សមីការនេះមានន័យកាលណា: $\begin{cases}4-2x\geq 0\\ x\geq 1\end{cases}\Leftrightarrow 1\leq x\leq 2$

យើងតាង: $t=\sqrt{x-1}+\sqrt{x+3};t>0\Rightarrow t^2=2x+2+\sqrt{(t-1)(t+3)}$

នោះសមីការខាងលើទៅជា: $t+t^2-6=0\Rightarrow\left[\begin{array}{l}t=2\\ t=-3\ \text{មិនយក}\end{array}\right.$

+ចំពោះ$t=2\Rightarrow\sqrt{x-1}+\sqrt{x+3}=2$

$$\Leftrightarrow 2x+2+2\sqrt{(x-1)(x+3)}=4\Leftrightarrow\sqrt{(x-1)(x+3)}=1-x$$

$$\Leftrightarrow\begin{cases}1-x\geq 0\\ 1\leq x\leq 2\\ \sqrt{(x-1)(x+3)}=1-x\end{cases}\Rightarrow x=1$$

ដូចនេះសមីការមានឫស: $x=1$ ។

ꕥ

**លំហាត់ទី១២:**ចូរដោះស្រាយសមីការខាងក្រោម:

$A. x+\sqrt{x}+\sqrt{x+2}+\sqrt{x^2+2x}=3$

$B. x^2+\sqrt{2-x}=2x^2\sqrt{2-x}$

$C. \sqrt{1-x}+\sqrt{1+x}=2-\dfrac{x^2}{4}$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងចូលវិស្វករអគ្គិសនីរុស្ស៊ី***

យើងមានសមីការ: $A. x+\sqrt{x}+\sqrt{x+2}+\sqrt{x^2+2x}=3$

សមីការនេះមានន័យកាលណា: $x\geq 0$

យើងតាង: $t=\sqrt{x}+\sqrt{2+x};t>0\Rightarrow t^2=2(x+1)+2\sqrt{x^2+2x}$

$$\Rightarrow x+1+\sqrt{x^2+2x}=\frac{t^2}{2}$$

នោះសមីការខាងលើទៅជា: $\frac{t^2}{2}+t=4 \Leftrightarrow t^2+2t-8=0 \Leftrightarrow \left[\begin{array}{l} t=2 \\ t=-4 \text{ មិនយក} \end{array}\right.$

+បើ $t=2$ នោះគេបាន: $\sqrt{x}+\sqrt{2+x}=2$

$\Leftrightarrow 2x+2+2\sqrt{x^2+2x}=4$

$\Leftrightarrow \sqrt{x^2+2x}=1-x \Leftrightarrow \begin{cases} 0\le x\le 1 \\ x^2+2x=x^2-2x+1 \end{cases} \Leftrightarrow \begin{cases} 0\le x\le 1 \\ x=\frac{1}{4} \end{cases} \Rightarrow x=\frac{1}{4}$

ដូចនេះសមីការមានរឹស: $x=\frac{1}{4}$ ។

យើងមានសមីការ: $B.\, x^2+\sqrt{2-x}=2x^2\sqrt{2-x}$

សមីការនេះមានន័យកាលណា: $2-x\ge 0 \Rightarrow x\le 2$

យើងតាង: $y=\sqrt{2-x}; y\ge 0$

$\Rightarrow y^2=2-x \Rightarrow x^2=\left(2-y^2\right)^2=y^4-4y^2+4$

នោះសមីការខាងលើទៅជា: $y^4-4y^2+4+y=2\left(y^4-4y^2+4\right).y$

$\Leftrightarrow 2y^5-y^4-8y^3+4y^2+7y-4=0$

$\Leftrightarrow (y-1)\left(2y^4+y^3-7y^2-3y+4\right)=0$

$\Leftrightarrow \left[\begin{array}{l} y=1 \\ 2y^4+y^3-7y^2-3y+4=0 \end{array}\right.$

$\Leftrightarrow \left[\begin{array}{l} y=1 \\ \left(y^2+y-1\right)\left(2y^2-y-4\right)=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} y=1 \\ y^2+y-1=0 \\ 2y^2-y-4=0 \end{array}\right.$

$$\Leftrightarrow \left[\begin{array}{l} y=1 \\ \left(y^2+y-1\right)\left(2y^2-y-4\right)=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} y=1 \\ y^2+y-1=0 \\ 2y^2-y-4=0 \end{array}\right.$$

$$\Leftrightarrow \left[\begin{array}{l} y=1 \\ y=\dfrac{-1-\sqrt{5}}{2} \text{ មិនយក} \\ y=\dfrac{\sqrt{5}-1}{2} \\ y=\dfrac{1-\sqrt{33}}{4} \text{ មិនយក} \\ y=\dfrac{1+\sqrt{33}}{4} \end{array}\right. \Leftrightarrow \left[\begin{array}{l} y=1 \\ y=\dfrac{\sqrt{5}-1}{2} \\ y=\dfrac{1+\sqrt{33}}{4} \end{array}\right.$$

+បើ $y=1 \Leftrightarrow \sqrt{2-x}=1 \Rightarrow x=1$

+បើ $y=\dfrac{\sqrt{5}-1}{2} \Leftrightarrow \sqrt{2-x}=\dfrac{\sqrt{5}-1}{2} \Rightarrow x=\dfrac{1+\sqrt{5}}{2}$

+បើ $y=\dfrac{1+\sqrt{33}}{4} \Leftrightarrow \sqrt{2-x}=\dfrac{1+\sqrt{33}}{4} \Leftrightarrow x=-\dfrac{1+\sqrt{33}}{8}$

ដូចនេះសមីការមានរឹសៈ $x=1,\ x=\dfrac{1+\sqrt{5}}{2}, x=-\dfrac{1+\sqrt{33}}{8}$ ។

យើងមានសមីការៈ $C. \sqrt{1-x}+\sqrt{1+x}=2-\dfrac{x^2}{4}$

សមីការនេះមានន័យកាលណាៈ $-1 \le x \le 1$

យើងតាងៈ $t=\sqrt{1-x}+\sqrt{1+x}; t \ge 0 \Rightarrow t^2=2+2\sqrt{1-x^2}$

$\Rightarrow x^2 = t^2 - \frac{1}{4}t^4$ នោះសមីការខាងលើទៅជា: $t = 2 - \frac{1}{4}\left(t^2 - \frac{t^4}{4}\right)$

$$\Leftrightarrow t = 2 - \frac{t^2}{4} + \frac{t^4}{16} \Leftrightarrow t^4 - 4t^2 - 16t + 32 = 0$$

$$\Leftrightarrow (t-2)\left(t^3 + 2t^2 - 16\right) = 0$$

$$\Leftrightarrow (t-2)^2\left(t^2 + 4t + 8\right) = 0 \Leftrightarrow t = 2$$

+បើ $t = 2 \Leftrightarrow \sqrt{1+x} + \sqrt{1-x} = 2 \Leftrightarrow x = 0$

ដូចនេះគេបានសមីការមានឫស: $x = 0$ ។

**លំហាត់ទី១៣:** ចូរដោះស្រាយសមីការខាងក្រោម:

$$A.\ \frac{2002x^4 + x^4\sqrt{x^2 + 2002} + x^2}{2001} = 2002$$

$$B.\ \sqrt{3 + x^2 - x} - \sqrt{2 + x - x^2} = 1$$

$$C.\ \sqrt{(1+x)(2-x)} = 1 + 2x - 2x^2$$

***ដកស្រង់ចេញពីវិញ្ញាសាត្រៀមប្រលងសិស្សពូកែវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ \frac{2002x^4 + x^4\sqrt{x^2 + 2002} + x^2}{2001} = 2002$

យើងតាង: $a = 2002; a > 0$ នោះសមីការទៅជា: $\frac{ax^4 + x^4\sqrt{x^2 + a} + x^2}{a - 1} = a$

$$\Leftrightarrow ax^4 + x^4\sqrt{x^2 + a} + x^2 = a^2 - a$$

$$\Leftrightarrow x^4\left(a+\sqrt{x^2+a}\right)+\left(\sqrt{x^2+a}\right)^2-a^2=0$$

$$\Leftrightarrow x^4\left(a+\sqrt{x^2+a}\right)+\left(\sqrt{x^2+a}-a\right)\left(\sqrt{x^2+a}+a\right)=0$$

$$\Leftrightarrow \left(\sqrt{x^2+a}+a\right)\left(x^4+\sqrt{x^2+a}-a\right)=0$$

$$\Leftrightarrow x^4+\sqrt{x^2+a}-a=0$$

$$\Leftrightarrow \left(x^2\right)^2-\left(\sqrt{x^2+a}\right)^2+x^2+\sqrt{x^2+a}=0$$

$$\Leftrightarrow \left(x^2-\sqrt{x^2+a}\right)\left(x^2+\sqrt{x^2+a}\right)+x^2+\sqrt{x^2+a}=0$$

$$\Leftrightarrow \left(x^2+\sqrt{x^2+a}\right)\left(x^2-\sqrt{x^2+a}+1\right)=0$$

$$\Leftrightarrow x^2-\sqrt{x^2+a}+1=0\ (*)$$

យើងតាង: $t=\sqrt{x^2+a}>1\Leftrightarrow t^2=x^2+a$ នោះសមីការ$(*)$ ទៅជា:

$$t^2-t+1-a=0\Rightarrow\left[\begin{array}{l} t=\dfrac{1-\sqrt{4a-3}}{2}<1 \text{ មិនយក} \\ t=\dfrac{1+\sqrt{4a-3}}{2} \end{array}\right.\Rightarrow x^2=\frac{1}{2}\left(\sqrt{4a-3}-1\right)$$

$$\Rightarrow x=\pm\sqrt{\frac{1}{2}\left(\sqrt{4a-3}-1\right)}$$

$$\Rightarrow x=\pm\sqrt{\frac{1}{2}\left(\sqrt{4.2002-3}-1\right)}$$

$$\Leftrightarrow x=\pm\sqrt{\frac{1}{2}\left(\sqrt{8005}-1\right)}$$

ដូចនេះគេបានសមីការមានរឹស: $x=\pm\sqrt{\frac{1}{2}\left(\sqrt{8005}-1\right)}$ ។

យើងមានសមីការ: $B.\sqrt{3+x^2-x}-\sqrt{2+x-x^2}=1$

សមីការនេះមានន័យកាលណា: $2+x-x^2\ge 0 \Leftrightarrow -1\le x\le 2$

យើងតាង: $t=x^2-x$ នោះសមីការខាងលើទៅជា: $\sqrt{3+t}-\sqrt{2-t}=1$

$$\Leftrightarrow \sqrt{3+t}=1+\sqrt{2-t} \Leftrightarrow \begin{cases}-3\le t\le 2\\ 3+t=3-t+2\sqrt{2-t}\end{cases}$$

$$\Leftrightarrow \begin{cases}-3\le t\le 2\\ \sqrt{2-t}=t\end{cases} \Leftrightarrow \begin{cases}0\le t\le 2\\ 2-t=t^2\end{cases} \Leftrightarrow \begin{cases}0\le t\le 2\\ \left[\begin{array}{l}t=1\\ t=-2\end{array}\right.\end{cases} \Leftrightarrow t=1$$

+បើ $t=1 \Leftrightarrow x^2-x-1=0 \Leftrightarrow \left[\begin{array}{l}x=\dfrac{1+\sqrt{5}}{2}\\ x=\dfrac{1-\sqrt{5}}{2}\end{array}\right.$

ដូចនេះសមីការមានឫស: $\left[\begin{array}{l}x=\dfrac{1+\sqrt{5}}{2}\\ x=\dfrac{1-\sqrt{5}}{2}\end{array}\right.$ ។

យើងមានសមីការ: $C.\ \sqrt{(1+x)(2-x)}=1+2x-2x^2$

សមីការនេះមានន័យកាលណា: $-1\le x\le 2$

យើងតាង: $t=\sqrt{2+x-x^2};t\ge 0 \Rightarrow t^2=2+x-x^2$

នោះសមីការខាងលើទៅជា:

$$t=2t^2-3 \Leftrightarrow 2t^2-t-3=0 \Leftrightarrow \begin{cases}t=-1 & \text{មិនយក}\\ t=\dfrac{3}{2}\end{cases}$$

+ចំពោះ $t=\dfrac{3}{2}\Leftrightarrow 2+x-x^2=\dfrac{9}{4}\Leftrightarrow x^2-x+\dfrac{1}{4}=0\Rightarrow x=\dfrac{1}{2}$

ដូចនេះសមីការមានរឹស: $x=\dfrac{1}{2}$ ។

យើងមានសមីការ: $D.\sqrt{x-1}+x-3=\sqrt{2(x-3)^2+2x-2}$

សមីការនេះមានន័យកាលណា: $x\geq 1$

យើងតាង: $\begin{cases}a=\sqrt{x-1}\geq 0\\ b=x-3\geq -2\end{cases}\Rightarrow\begin{cases}a^2=x-1\\ b^2=(x-3)^2\end{cases}$

នោះសមីការខាងលើទៅជា:

$$a+b=\sqrt{2b^2+2a^2}\Leftrightarrow\begin{cases}a+b\geq 0\\ (a+b)^2=2(a^2+b^2)\end{cases}$$

$$\Leftrightarrow\begin{cases}a+b\geq 0\\ (a-b)^2=0\end{cases}\Leftrightarrow\begin{cases}a+b\geq 0\\ a=b\end{cases}$$

+បើ $a=b$ នោះគេបាន: $\sqrt{x-1}=x-3\Rightarrow x=5$

ដូចនេះគេបានសមីការខាងលើមានរឹស: $x=5$ ។

**លំហាត់ទី១៤:** ចូរដោះស្រាយសមីការខាងក្រោម:

$$A.\ (x-3)\sqrt[3]{\frac{3-x}{x-1}}+(x-1)\sqrt[3]{\frac{x-1}{3-1}}=2$$

$$B.\ (x+3)\sqrt{10-x^2}=x^2-x-12$$

***ដកស្រង់ចេញពីការប្រលងសិស្សពូកែប៉ូឡូញ***

## ចំលើយ

យើងមានសមីការ: $A.\ (x-3)\sqrt[3]{\frac{3-x}{x-1}}+(x-1)\sqrt[3]{\frac{x-1}{3-1}}=2$

សមីការនេះមានន័យកាលណា: $\begin{cases} x\neq 1 \\ x\neq 3 \end{cases}$

យើងតាង: $t=\sqrt[3]{\frac{3-x}{x-1}}\Rightarrow\sqrt[3]{\frac{x-1}{3-x}}=\frac{1}{t}$ នោះសមីការទៅជា:

$\Leftrightarrow(3-x)t+(x-1)\frac{1}{t}=2\Leftrightarrow(3-x)t^2-2t+x-1=0$

$\Delta'=1-(3-x)(x-1)=x^2-4x+4=(x-2)^2$

$$\Rightarrow\left[\begin{array}{l} t=\frac{1-x+2}{3-x}=1 \\ t=\frac{1+x-2}{3-x}=\frac{x-1}{3-x} \end{array}\right.$$

+បើ $t=1\Leftrightarrow\frac{3-x}{x-1}=1\Leftrightarrow 3-x=x-1\Rightarrow x=2$

+បើ $t=\frac{x-1}{3-x}\Leftrightarrow\frac{3-x}{x-1}=\left(\frac{x-1}{3-x}\right)^3\Leftrightarrow(3-x)^4=(x-1)^4$

$\Leftrightarrow 3-x=x-1\Rightarrow x=2$

ដូចនេះសមីការមានរឹស: $x=2$ ។

យើងមានសមីការ: $B.\ (x+3)\sqrt{10-x^2}=x^2-x-12$

សមីការនេះមានន័យកាលណា: $|x|\leq\sqrt{10}$

យើងបានសមីការ: $(x+3)\sqrt{10-x^2}=(x+3)(x-4)$

$\Leftrightarrow (x+3)\left(\sqrt{10-x^2}-x+4\right)=0$

$\Leftrightarrow \left[\begin{array}{l} x=-3 \\ \sqrt{10-x^2}=x+4 \end{array}\right.$ មិនយកព្រោះ $|x|\le\sqrt{10}\Rightarrow x-4<0$

$\Rightarrow x=-3$ ជាឫស

ដូចនេះសមីការមានឫស: $x=-3$ ។

**លំហាត់ទី១៥:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x^2+x+12\sqrt{x+1}=36$

$B.\sqrt{x-1}+\sqrt{x^3+x^2+x+1}=1+\sqrt{x^4-1}$

***ដកស្រង់ចេញពីលំហាត់ត្រៀមប្រលងចូលមហាវិទ្យាល័យវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ x^2+x+12\sqrt{x+1}=36$

សមីការនេះមានន័យកាលណា: $x\ge -1$

យើងតាង: $t=\sqrt{x+1};t\ge 0\Rightarrow x=t^2-1$ នោះសមីការខាងលើទៅជា:

$\left(t^2-1\right)^2+t^2-1+12t-36=0$

$\Leftrightarrow t^4-t^2+12t-36=0\Leftrightarrow (t-2)\left(t^3+2t^2+3t+18\right)=0$

$\Rightarrow \left[\begin{array}{l} t=2 \\ t^3+2t^2+3t+18 \end{array}\right.$ មិនពិតព្រោះ $t\ge 0$

+បើ $t=2$ នោះគេបាន: $x=3$

ដូចនេះសមីការមានរឹសៈ $x = 3$ ។

យើងមានសមីការៈ $B.\sqrt{x-1}+\sqrt{x^3+x^2+x+1}=1+\sqrt{x^4-1}$ ស

សមីការនេះមានន័យកាលណាៈ $x \ge 1$

យើងតាងៈ

$$\begin{cases} a=\sqrt{x-1}\ge 0 \\ b=\sqrt{x^3+x^2+x+1}>0 \end{cases} \Rightarrow a.b=\sqrt{(x-1)\left(x^3+x^2+x+1\right)}=\sqrt{x^4-1}$$

នោះសមីការខាងលើទៅជាៈ $a+b=1+ab$

$$\Leftrightarrow a(1-b)-(1-b)=0 \Leftrightarrow (1-b)(a-1)=0 \Rightarrow \left[\begin{array}{l} a=1 \\ b=1 \end{array}\right.$$

+ចំពោះ $a=1 \Leftrightarrow \sqrt{x-1}=1 \Rightarrow x=2$

+ចំពោះ $b=1 \Leftrightarrow \sqrt{x^3+x^2+x+1}=1 \Leftrightarrow x\left(x^2+x+1\right)=0 \Rightarrow x=0$ មិនយក

ដូចនេះគេបានសមីការមានរឹសៈ $x = 2$ ។

**លំហាត់ទី១៦:** ចូរដោះស្រាយសមីការខាងក្រោមៈ

$A.\left(x+3\sqrt{x}+2\right)\left(x+9\sqrt{x}+18\right)=168x$

$B.\ \left(\sqrt{x^2+1}-x\right)^5+\left(\sqrt{x^2+1}+x\right)^5=123$

***ដកស្រង់ចេញពីកំរងលំហាត់ប្រលងចូលមហាវិទ្យាល័យវៀតណាម***

**ចំលើយ**

យើងមានសមីការ: $A.\left(x+3\sqrt{x}+2\right)\left(x+9\sqrt{x}+18\right)=168x$

សមីការនេះមានន័យកាលណា: $x\ge 0$ នោះសមីការអាចសរសេរ:

$$\left(\sqrt{x}+1\right)\left(\sqrt{x}+2\right)\left(\sqrt{x}+3\right)\left(\sqrt{x}+6\right)=168x$$

$$\Leftrightarrow \left(x+5\sqrt{x}+6\right)\left(x+7\sqrt{x}+6\right)=168x$$

$$\Leftrightarrow \left(x+6\sqrt{x}-\sqrt{x}+6\right)\left(x+6\sqrt{x}+6+\sqrt{x}\right)=168x$$

$$\Leftrightarrow \left(x+6\sqrt{x}+6\right)^2=169x=\left(13\sqrt{x}\right)^2$$

$$\Leftrightarrow \begin{cases} x+6\sqrt{x}+6=13\sqrt{x} \\ x+6\sqrt{x}+6=-13\sqrt{x} \text{ មិនយកព្រោះ } x\ge 0 \end{cases}$$

$$\Leftrightarrow x-7\sqrt{x}+6=0$$

$$\Leftrightarrow \left[\begin{array}{l} \sqrt{x}=1 \\ \sqrt{x}=6 \end{array}\right. \Leftrightarrow \left[\begin{array}{l} x=1 \\ x=36 \end{array}\right.$$

ដូចនេះគេបានសមីការមានរឹស: $x=1\vee x=36$ ។

យើងមានសមីការ: $B.\left(\sqrt{x^2+1}-x\right)^5+\left(\sqrt{x^2+1}+x\right)^5=123$

ដោយយើងដឹងថា: $\left(\sqrt{x^2+1}-1\right)\left(\sqrt{x^2+1}+1\right)=1$ នោះយើងតាង:

$t=\sqrt{x^2+1}-1\Rightarrow\sqrt{x^2+1}+1=\dfrac{1}{t}$ នោះសមីការខាងលើទៅជា:

$$t=\sqrt{x^2+1}-1\Rightarrow\sqrt{x^2+1}+1=\frac{1}{t}$$

$t^5+\frac{1}{t^5}=123\Leftrightarrow t^{10}-123t^5+1=0$ យើងតាង:

$$y=t^5\Rightarrow y^5-123y+1=0\Rightarrow\left[\begin{array}{l}y=\frac{123-55\sqrt{5}}{2}\\ y=\frac{123+55\sqrt{5}}{2}\end{array}\right.$$

$$\Rightarrow\left[\begin{array}{l}t^5=\frac{123-55\sqrt{5}}{2}=\left(\frac{3-\sqrt{5}}{2}\right)^5\\ t^5=\frac{123+55\sqrt{5}}{2}=\left(\frac{3+\sqrt{5}}{2}\right)^5\end{array}\right.\Leftrightarrow\left[\begin{array}{l}t=\frac{3-\sqrt{5}}{2}\\ t=\frac{3+\sqrt{5}}{2}\end{array}\right.$$

+បើ $t=\frac{3-\sqrt{5}}{2}\Leftrightarrow\sqrt{x^2+1}-x=\frac{3-\sqrt{5}}{2}\Leftrightarrow\sqrt{x^2+1}=\frac{3-\sqrt{5}}{2}+x$

$$\Leftrightarrow\begin{cases}x\geq\frac{\sqrt{5}-3}{2}\\ x^2+1=x^2+\left(3-\sqrt{5}\right)x+\left(\frac{3-\sqrt{5}}{2}\right)^2\end{cases}\Leftrightarrow\begin{cases}x\geq\frac{\sqrt{5}-3}{2}\\ x=\frac{\sqrt{5}}{2}\end{cases}\Rightarrow x=\frac{\sqrt{5}}{2}$$

+បើ $t=\frac{\sqrt{5}+3}{2}\Leftrightarrow\sqrt{x^2+1}-x=\frac{\sqrt{5}+3}{2}$

$$\Leftrightarrow\sqrt{x^2+1}=x+\frac{\sqrt{5}+3}{2}\Leftrightarrow\begin{cases}x\geq-\frac{3+\sqrt{5}}{2}\\ x^2+1=x^2+\left(\sqrt{5}+3\right)x+\left(\frac{\sqrt{5}+3}{2}\right)^2\end{cases}$$

$$\Leftrightarrow \sqrt{x^2+1}=x+\frac{\sqrt{5}+3}{2} \Leftrightarrow \begin{cases} x \ge -\frac{3+\sqrt{5}}{2} \\ x^2+1=x^2+\left(\sqrt{5}+3\right)x+\left(\frac{\sqrt{5}+3}{2}\right)^2 \end{cases}$$

$$\Leftrightarrow \begin{cases} x \ge -\frac{3+\sqrt{5}}{2} \\ x=-\frac{\sqrt{5}}{2} \end{cases} \Rightarrow x=-\frac{\sqrt{5}}{2}$$

ដូចនេះសមីការមានរឹស: $x=\pm\frac{\sqrt{5}}{2}$ ។

**លំហាត់ទី១៧:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ 2\sqrt[3]{(1+x)^2}+3\sqrt[3]{1-x^2}+\sqrt[3]{(1-x)^2}=0$

$B.\ \sqrt{x}+\sqrt{x+2}+2\sqrt{x^2+7x}=35-2x$

***ដកស្រង់ចេញពីកំរងលំហាត់ប្រលងចូលមហាវិទ្យាល័យវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ 2\sqrt[3]{(1+x)^2}+3\sqrt[3]{1-x^2}+\sqrt[3]{(1-x)^2}=0$

យើងចែកអង្គទាំងពីរនិង: $\sqrt[3]{1-x^2}$ នោះយើងបាន:

$2\sqrt[3]{\frac{x+1}{1-x}}+3+\sqrt[3]{\frac{1-x}{1+x}}=0$ យើងតាង: $t=\sqrt[3]{\frac{1+x}{1-x}} \Rightarrow \sqrt[3]{\frac{1-x}{1+x}}=\frac{1}{t}$

នោះសមីការខាងលើទៅជា: $2t+3+\frac{1}{t}=0$

$\Leftrightarrow 2t^2+3t+1=0 \Rightarrow \left[\begin{array}{l} t=-1 \\ t=-\frac{1}{2} \end{array}\right.$

+បើ $t=-1 \Leftrightarrow \sqrt[3]{\frac{1+x}{1-x}}=-1 \Leftrightarrow 1+x=x-1$ មិនពិត

+បើ $t=-\frac{1}{2} \Leftrightarrow \frac{1+x}{1-x}=-\frac{1}{8} \Leftrightarrow 8(x+1)=x-1 \Rightarrow x=-\frac{9}{7}$

ដូចនេះសមីការមានរឹស: $x=-\frac{9}{7}$ ។

យើងមានសមីការ: $\sqrt{x}+\sqrt{x+7}+2\sqrt{x^2+7x}=35-2x$

សមីការនេះមានន័យកាលណា: $0\le x\le \frac{35}{2}$ នោះសមីការអាចសរសេរ:

$\sqrt{x}+\sqrt{x+7}+2\sqrt{x^2+7x}+2x=35$ យើងតាង:

$t=\sqrt{x}+\sqrt{x+7}\,; t>0 \Rightarrow t^2=2x+7+2\sqrt{x^2+7x}$

$\Rightarrow 2x+2\sqrt{x^2+7x}=t^2-7$ នោះសមីការខាងលើទៅជា:

$t+t^2-7=35 \Leftrightarrow t^2+t-42=0 \Leftrightarrow \left[\begin{array}{l} t=-7 \text{ មិនយក} \\ t=6 \end{array}\right.$

+បើ $t=6 \Leftrightarrow \sqrt{x}+\sqrt{x+7}=6 \Leftrightarrow 2x+7+2\sqrt{x^2+7x}=36$

$\Leftrightarrow 2\sqrt{x^2+7x}=29-2x$

$\Leftrightarrow \begin{cases} 0\le x\le \frac{29}{2} \\ 4\left(x^2+7x\right)=4x^2-116x+29^2 \end{cases}$

$$\Leftrightarrow \begin{cases} 0 \le x \le \dfrac{29}{2} \\ x = \dfrac{29^2}{144} \end{cases}$$

ដូចនេះសមីការមានរឹស: $x = \left(\dfrac{29}{12}\right)^2$ ។

"ពេលបំពេញកិច្ចការអ្វីមួយមិនថាតូចតាចប៉ុណ្ណាក្តី ចូរដាក់ចិត្ត ប្រមូលអារម្មណ៍ និង បញ្ញារបស់អ្នក"ឡ

**លំហាត់ទី១៨:**ចូរដោះស្រាយសមីការខាងក្រោម:

$A.\sqrt{x^2+2x}+\sqrt{2x-1}=\sqrt{3x^2+4x+1}$

$B.\sqrt[3]{\dfrac{2x}{x+1}}+\sqrt[3]{\dfrac{1}{2}+\dfrac{1}{2x}}=2$

***ដកស្រង់ចេញពីវិញ្ញាប្រលងនៅប្រទេសចិនប្រជាមានិត***

## ចំលើយ

យើងមានសមីការ: $A.\sqrt{x^2+2x}+\sqrt{2x-1}=\sqrt{3x^2+4x+1}$

សមីការនេះមានន័យកាលណា: $x \ge \dfrac{1}{2}$ យើងតាង:

$$\begin{cases} a=\sqrt{2x-1}\ge 0 \\ b=\sqrt{3x^2+4x+1}\ge 0 \end{cases} \Rightarrow \begin{cases} a^2 = 2x-1 \\ b^2 = 3x^2+4x+1 \end{cases}$$

$$\begin{cases} a=\sqrt{2x-1}\ge 0 \\ b=\sqrt{3x^2+4x+1}\ge 0 \end{cases} \Rightarrow \begin{cases} a^2=2x-1 \\ b^2=3x^2+4x+1 \end{cases}$$

$$\Rightarrow a^2+b^2=3x^2+6x=3\left(x^2+2x\right)$$

$$\Rightarrow x^2+2x=\frac{a^2+b^2}{3}$$

នោះសមីការខាងលើទៅជា: $\sqrt{\frac{a^2+b^2}{3}}=b-a$

$$\Leftrightarrow \begin{cases} b-a\ge 0 \\ \frac{a^2+b^2}{3}=(b-a)^2 \end{cases} \Leftrightarrow \begin{cases} b\ge a \\ a^2+b^2-3ab=0\ (*) \end{cases}$$

+ករណី: $b\ge a \Leftrightarrow \sqrt{3x^2+4x+1}\ge\sqrt{2x-1}$

$\Leftrightarrow 3x^2+2x+2\ge 0\,\forall x\in IR$ នោះ $(*)$ $a^2-3ba+b^2=0$

$$\Delta=9b^2-4b^2=5b^2 \Rightarrow \left[\begin{array}{l} a=\frac{3b-\sqrt{5}b}{2} \\ a=\frac{3b+\sqrt{5}b}{2} \end{array}\right.$$

+បើ $a=\frac{3-\sqrt{5}}{2}b$ នោះយើងបាន: $\sqrt{2x-1}=\frac{3-\sqrt{5}}{2}\sqrt{3x^2+4x+1}$

$$\Leftrightarrow 2x-1=\frac{7-3\sqrt{5}}{2}\left(3x^2+4x+1\right)$$

$$\Leftrightarrow 3\left(7-3\sqrt{5}\right)x^2+4\left(6-3\sqrt{5}\right).+9-3\sqrt{5}=0$$

យើងដោះស្រាយសមីការនេះយើងបាន: $x=\frac{\left(3\sqrt{5}-6\right)4}{6\left(7-3\sqrt{5}\right)}=\frac{\sqrt{5}+1}{2}$

+បើ $x=\frac{3+\sqrt{5}}{2}b \Leftrightarrow \sqrt{2x-1}=\frac{3+\sqrt{5}}{2}.\sqrt{3x^2+4x+1}$

$\Leftrightarrow 2x-1=\frac{7-3\sqrt{5}}{2}\left(3x^2+4x+1\right)$

$\Leftrightarrow 3\left(7+3\sqrt{5}\right)x^2+4\left(6+3\sqrt{5}\right)x+9+3\sqrt{5}=0$

យើងដោះស្រាយសមីការនេះយើងបាន: $x=\frac{4\left(6+3\sqrt{5}\right)}{6\left(7+3\sqrt{5}\right)}=\frac{1-\sqrt{5}}{2}$ មិនយក

ដូចនេះសមីការមានរឹស: $x=\frac{\sqrt{5}+1}{2}$ ។

យើងមានសមីការ: $B.\sqrt[3]{\frac{2x}{x+1}}+\sqrt[3]{\frac{1}{2}+\frac{1}{2x}}=2$

សមីការនេះមានន័យកាលណា: $x\neq 0$ យើងតាង: $t=\sqrt[3]{\frac{2x}{1+x}}\Rightarrow\sqrt[3]{\frac{1+x}{2x}}=\frac{1}{t}$

នោះសមីការខាងលើទៅជា: $t+\frac{1}{t}=2\Rightarrow t=1\Leftrightarrow\frac{2x}{1+x}=1\Rightarrow x=1$

ដូចនេះសមីការមានរឹស: $x=1$ ។

**លំហាត់ទី១៩:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\sqrt{5x^2+14x+9}-\sqrt{x^2-x-20}=5\sqrt{x+1}$

$B.5\sqrt{1+x^3}=2\left(x^2+2\right)$

***ដកស្រង់ចេញពីការប្រលងចូលមធ្យមសិក្សាក៏រិតពីប្រទេសចិន***

**ចំលើយ**

យើងមានសមីការ: $A.\sqrt{5x^2+14x+9}-\sqrt{x^2-x-20}=5\sqrt{x+1}$

សមីការនេះមានន័យកាលណា:

$$\begin{cases}5x^2+14x+9\ge 0\\ x^2-x-20\ge 0\\ x\ge -1\end{cases}\Leftrightarrow\begin{cases}\left[\begin{array}{l}x\le -\frac{9}{5}\\ x\ge -1\end{array}\right.\\ x\ge 5\vee x\le -4\Leftrightarrow x\ge 5\\ x\ge -1\end{cases}$$

នោះសមីការខាងលើអាចសរសេរ: $\sqrt{5x^2+14x+9}=\sqrt{x^2-x-20}+5\sqrt{x+1}$

$$\Leftrightarrow\sqrt{(x+1)(5x+1)}=\sqrt{(x+4)(x-5)}+5\sqrt{x+1}$$

$$\Leftrightarrow(x+1)(5x+9)=(x+4)(x-5)+25(x+1)+10\sqrt{(x+1)(x+4)(x+5)}$$

$$\Leftrightarrow 2\left(x^2-4x-5\right)+3(x+4)=5\sqrt{\left(x^2-4x-5\right)(x+4)}$$

យើងតាង: $\begin{cases}a=\sqrt{x^2-4x-5}\\ b=\sqrt{x+4}\end{cases}$ នោះសមីការនេះទៅជា:

$$2a^2+3b^2=5a\Leftrightarrow 2a^2-5ba+3b^2=0\Rightarrow\left[\begin{array}{l}a=b\\ a=\frac{3b}{2}\end{array}\right.$$

+បើ $a=b\Leftrightarrow\sqrt{x^2-4x-5}=\sqrt{x+4}\Leftrightarrow x^2-4x-5=x+4$

$$\Leftrightarrow x^2-5x-9=0\Rightarrow\left[\begin{array}{l}x=\frac{5+\sqrt{61}}{2}\\ x=\frac{5-\sqrt{61}}{2}\ \text{មិនយក}\end{array}\right.$$

+បើ $a=\frac{3}{2}b\Leftrightarrow\sqrt{x^2-4x-5}=\frac{3}{2}\sqrt{x+4}\Leftrightarrow 4\left(x^2-4x-5\right)=9\left(x+4\right)$

$\Leftrightarrow 4x^2-25x-56=0\Rightarrow\left[\begin{array}{l}x=8\\ x=-\frac{7}{4}\text{ មិនយក}\end{array}\right.$

ដូចនេះសមីការមានរឹស: $x=\frac{5+\sqrt{61}}{2}\vee x=8$ ។

យើងមានសមីការ: $B.5\sqrt{1+x^3}=2\left(x^2+2\right)$

សមីការនេះមានន័យកាលណា: $x\geq -1$ នោះគេអាចសរសេរ:

$\Leftrightarrow 5\sqrt{(x+1)\left(x^2-x+1\right)}=2\left(x^2+2\right)$ យើងតាង:

$\begin{cases}a=\sqrt{x+1}\geq 0\\ b=\sqrt{x^2-x+1}\geq 0\end{cases}\Leftrightarrow\begin{cases}a^2=x+1\\ b^2=x^2-x+1\end{cases}\Rightarrow a^2+b^2=x^2+2$

នោះសមីការខាងលើទៅជា: $5ab=2\left(a^2+b^2\right)$

$\Leftrightarrow 2a^2-5ab+2b^2=0\Rightarrow\left[\begin{array}{l}a=\frac{b}{2}\\ a=2b\end{array}\right.$

+បើ $a=\frac{b}{2}\Leftrightarrow 2\sqrt{x+1}=\sqrt{x^2-x+1}$

$\Leftrightarrow x+1=4\left(x^2-x+1\right)\Leftrightarrow x^2-5x-3=0\Rightarrow\left[\begin{array}{l}x=\frac{5-\sqrt{37}}{2}\\ x=\frac{5+\sqrt{37}}{2}\end{array}\right.$

+បើ $a=2b\Leftrightarrow\sqrt{x+1}=2\sqrt{x^2-x+1}$

$\Leftrightarrow x+1=4\left(x^2-x+1\right)$

$\Leftrightarrow 4x^2-5x+3=0$ គ្មានរឹស

ដូចនេះសមីការមានរឹស: $x=\dfrac{5\pm\sqrt{37}}{2}$

" បរាជ័យជាពេលវេលា ឈប់សំរាកសំរាប់បន្តដំណើរទៅមុខទៀត"

**លំហាត់ទី២០:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ \sqrt[3]{7x+1}-\sqrt[3]{x^2-x-8}+\sqrt[3]{x^2-8x-1}=2$

$B.\left(x+3\sqrt{x}+2\right)\left(x+9\sqrt{x}+18\right)=120\sqrt{x}$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងនៅប្រទេសបារាំង***

## ចំលើយ

យើងមានសមីការ: $A.\ \sqrt[3]{7x+1}-\sqrt[3]{x^2-x-8}+\sqrt[3]{x^2-8x-1}=2$

យើងតាង: $\begin{cases} a=\sqrt[3]{7x+1} \\ b=-\sqrt[3]{x^2-x-8} \\ c=\sqrt[3]{x^2-8x-1} \end{cases} \Rightarrow \begin{cases} a^3=7x+1 \\ b^3=-\left(x^2-x-8\right) \\ c^3=x^2-8x-1 \end{cases}$

នោះសមីការខាងលើទៅជា: $a+b+c=2 \Rightarrow (a+b+c)^3=8(*)$

យើងពិនិត្យសមីការ: $a^3+b^3+c^3=8$ (ការបូកអង្គទាំងអស់) $(**)$

តាម $(*)$ និង $(**)$ គេបាន: $(a+b+c)^3=a^3+b^3+c^3$

$\Leftrightarrow a^3+b^3+c^3=(a+b)^3+c^3+3(a+b)^2c+3c^2(a+b)$

$\Leftrightarrow a^3+b^3+c^3=a^3+b^3+c^3+3a^2b+3ab^2+3a^2c+3b^2c$

$+6abc+3c^2a+3c^2b$

$\Leftrightarrow a^2b+ab^2+a^2c+b^2c+c^2a+c^2b+2abc=0$

$$\Leftrightarrow (a+b)(b+c)(c+a)=0\Rightarrow \left[\begin{array}{l} a=-b \\ b=-c \\ c=-a \end{array}\right.$$

+បើ $b=-c\Leftrightarrow \sqrt[3]{7x+1}=\sqrt[3]{x^2-x-8}\Leftrightarrow 7x+1=x^2-x-8$

$$\Leftrightarrow x^2-8x-9=0\Rightarrow \left[\begin{array}{l} x=-1 \\ x=9 \end{array}\right.$$

+បើ $b=-c\Leftrightarrow \sqrt[3]{x^2-x-8}=\sqrt[3]{x^2-8x-1}\Rightarrow x=1$

+បើ $c=-a\Leftrightarrow \sqrt[3]{x^2-8x-1}=-\sqrt[3]{7x+1}\Leftrightarrow x^2-8x-1=-7x-1$

$$\Leftrightarrow x^2-x=0\Rightarrow \left[\begin{array}{l} x=0 \\ x=1 \end{array}\right.$$

ដូចនេះសមីការមានសំណុំរឺស: $x=\{-1,0,1,9\}$ ។

យើងមានសមីការ: $B.\left(x+3\sqrt{x}+2\right)\left(x+9\sqrt{x}+18\right)=120\sqrt{x}$

សមីការនេះមានន័យកាលណា: $x\geq 0$ ។ សមីការនេះអាចសរសេរ:

$\Leftrightarrow \left(\sqrt{x}+1\right)\left(\sqrt{x}+2\right)\left(\sqrt{x}+3\right)\left(\sqrt{x}+6\right)=120\sqrt{x}$

$\Leftrightarrow \left[\left(\sqrt{x}+1\right)\left(\sqrt{x}+6\right)\right]\left[\left(\sqrt{x}+2\right)\left(\sqrt{x}+3\right)\right]=120\sqrt{x}$

$\Leftrightarrow \left(x+7\sqrt{x}+6\right)\left(x+5\sqrt{x}+6\right)=120\sqrt{x}$

យើងចែកអង្គទាំងពីរនៃសមីការនិង $\sqrt{x}$ នោះគេបាន:

$$\Leftrightarrow\left(\sqrt{x}+\frac{6}{\sqrt{x}}+7\right)\left(\sqrt{x}+\frac{6}{\sqrt{x}}+5\right)=120$$

យើងតាង: $t=\sqrt{x}+\frac{6}{\sqrt{x}}$; $t\geq 2\sqrt{6}$ នោះសមីការខាងលើទៅជា:

$$(t+7)(t+5)=120\Leftrightarrow t^2+12t-85=0\Rightarrow\left[\begin{array}{l}t=-17 \text{ មិនយក}\\ t=5\end{array}\right.$$

+បើ $t=5\Leftrightarrow\sqrt{x}+\frac{6}{\sqrt{x}}=5\Leftrightarrow x-5\sqrt{x}+6=0\Rightarrow\left[\begin{array}{l}x=4\\ x=9\end{array}\right.$

ដូចនេះសមីការមានរឹស: $x=4\vee x=9$ ។

**" តើក្នុងជីវិតមនុស្សម្នាក់ មានបរាជ័យប៉ុន្មានដង និង ជោគជ័យប៉ុន្មានដង?"ឡ**

**លំហាត់ទី២១:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ 2x^2+\sqrt{x-1}+2x\sqrt{1-x^2}=1$

$B.\ 1+\frac{3}{2}\sqrt{x-x^2}=\sqrt{x}+\sqrt{1-x}$

***ដកស្រង់ចេញពីកំរងលំហាត់ប្រលងនៅប្រទេសអ៊ុយក្រែន***

## ចំលើយ

យើងមានសមីការ: $A.\ 2x^2+\sqrt{x-1}+2x\sqrt{1-x^2}=1$

សមីការនេះមានន័យកាលណា: $-1\le x\le 1$ ។ សមីការនេះអាចសរសេរ:

$\sqrt{1-x}=1-2x^2-2x\sqrt{1-x^2}$

$\Rightarrow 1-x=1+4x^4+4x^2\left(1-x^2\right)-4x^2+8x^3\sqrt{1-x^2}-4x\sqrt{1-x^2}$

$\Rightarrow x\left(1+8x^2\sqrt{1-x^2}-4\sqrt{1-x^2}\right)=0$

$\Rightarrow \left[\begin{array}{l} x=0 \\ 1+8x^2\sqrt{1-x^2}-4\sqrt{1-x^2}=0(*) \end{array}\right.$

យើងតាង: $t=\sqrt{1-x^2};t\ge 0$ នោះគេបាន: $x^2=1-t^2$

នោះសមីការ $(*)$ ទៅជា: $8\left(1-t^2\right)t-4t+1=0$

$\Leftrightarrow 8t^3-4t-1=0\Leftrightarrow\left(t+\frac{1}{2}\right)\left(8t^2-4t-2\right)=0$

$\Leftrightarrow \left[\begin{array}{l} t+\frac{1}{2}=0 \text{ មិនយកព្រោះ } t\ge 0 \\ 4t^2-2t-1=0\Rightarrow t=\frac{1+\sqrt{5}}{4} \end{array}\right.$

+បើ $t=\frac{1+\sqrt{5}}{4}\Leftrightarrow x^2=1-\left(\frac{1+\sqrt{5}}{4}\right)^2=\frac{5-\sqrt{5}}{8}\Rightarrow x=\pm\sqrt{\frac{5-\sqrt{5}}{8}}$

ដូចនេះយើងបានសមីការមានរឹស: $x=0\vee x=-\sqrt{\frac{5-\sqrt{5}}{8}}$ ។

យើងមានសមីការ: $B.1+\frac{3}{2}\sqrt{x-x^2}=\sqrt{x}+\sqrt{1-x}$

សមីការនេះមានន័យកាលណា: $0\le x\le 1$ យើងតាង: $t=\sqrt{x}+\sqrt{1-x};t>0$

$\Rightarrow t^2=1+2\sqrt{x-x^2}\Rightarrow\sqrt{x-x^2}=\dfrac{t^2-1}{2}$ នោះសមីការខាងលើទៅជា:

$$1+\frac{3}{4}\left(t^2-1\right)=t\Leftrightarrow 3t^2-4t+1=0\Rightarrow\left[\begin{array}{l}t=1\\ t=\dfrac{1}{3}\end{array}\right.$$

+បើ $t=1\Leftrightarrow\sqrt{x}+\sqrt{1-x}=1\Rightarrow\left[\begin{array}{l}x=0\\ x=1\end{array}\right.$

+បើ $t=\dfrac{1}{3}\Leftrightarrow\sqrt{x}+\sqrt{1-x}=\dfrac{1}{3}\Leftrightarrow x+2\sqrt{x(1-x)}+1-x=\dfrac{1}{9}$

$\Leftrightarrow 2\sqrt{x(1-x)}=-\dfrac{8}{9}\Leftrightarrow\sqrt{x-x^2}=-\dfrac{8}{18}$ មិនយក

ដូចនេះសមីការមានរឹស: $x=0\vee x=1$ ។

**លំហាត់ទី២២:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\left(x+5\right)\left(2-x\right)=3\sqrt{x^2+3x}$

$B.\sqrt[3]{(2-x)^2}+\sqrt[3]{(7+x)^2}=3+\sqrt[3]{(7+x)(2-x)}$

***ដកស្រង់ចេញពីការប្រលងជ្រើសរើសសិស្សពូកែទីក្រុងស៊ាងហៃប្រទេសចិន***

## ចំលើយ

យើងមានសមីការ: $A.\left(x+5\right)\left(2-x\right)=3\sqrt{x^2+3x}$

សមីការនេះមានន័យកាលណា: $\left[\begin{array}{l}x\le -3\\ x\ge 0\end{array}\right.$ សមីការនេះយើងអាចសរសេរ:

$\Leftrightarrow -\left(x^2+3x\right)+10=3\sqrt{x^2+3x}$ យើងតាង: $t=\sqrt{x^2+3x};t\geq 0$

នោះសមីការខាងលើទៅជា: $t^2+3t-10=0\Leftrightarrow \left[\begin{array}{l} t=-5 \text{ មិនយក} \\ t=2 \end{array}\right.$

+បើ $t=2\Leftrightarrow \sqrt{x^2+3x}=2\Leftrightarrow x^2+3x-4=0\Rightarrow \left[\begin{array}{l} x=1 \\ x=-4 \end{array}\right.$

ដូចនេះសមីការមានរឹស: $x=1,x=-4$ ។

យើងមានសមីការ: $B.\sqrt[3]{(2-x)^2}+\sqrt[3]{(7+x)^2}=3+\sqrt[3]{(7+x)(2-x)}$

យើងតាង: $\begin{cases} a=\sqrt[3]{2-x} \\ b=\sqrt[3]{7+x} \end{cases}\Rightarrow \begin{cases} a^3=2-x \\ b^3=7+x \end{cases}\Rightarrow a^3+b^3=9$

នោះសមីការខាងលើទៅជា:

$\Leftrightarrow \begin{cases} a^2+b^2-ab=3 \\ a^3+b^3=9 \end{cases}\Leftrightarrow \begin{cases} a^2+b^2-ab=3 \\ (a+b)\left(a^2+b^2-ab\right)=9 \end{cases}\Leftrightarrow \begin{cases} a^2+b^2-ab=3 \\ a+b=3 \end{cases}$

$\Leftrightarrow \begin{cases} a+b=3 \\ (a+b)^3-3ab=3 \end{cases}\Leftrightarrow \begin{cases} a+b=3 \\ ab=2 \end{cases}$

នោះយើងបាន $a,b$ ជារឹសនៃសមីការនោះតាមវ្យែតយើងបានសមីការ:

$X^2-3X+2=0\Rightarrow \left[\begin{array}{l} X=1 \\ X=2 \end{array}\right.\Rightarrow \begin{cases} a=1 \\ b=2 \end{cases}\vee \begin{cases} a=2 \\ b=1 \end{cases}$

+ចំពោះ $\begin{cases} a=1 \\ b=2 \end{cases}\Leftrightarrow \begin{cases} \sqrt[3]{2-x}=1 \\ \sqrt[3]{7+x}=2 \end{cases}\Rightarrow \begin{cases} x=1 \\ x=1 \end{cases}\Rightarrow x=1$

+ចំពោះ $\begin{cases} a=2 \\ b=1 \end{cases}\Leftrightarrow \begin{cases} \sqrt[3]{2-x}=2 \\ \sqrt[3]{7+x}=1 \end{cases}\Rightarrow \begin{cases} x=-6 \\ x=-6 \end{cases}\Rightarrow x=-6$

ដូចនេះសមីការមានរឹស: $x=-6;x=1$ ។

**លំហាត់ទី២៣:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x-2\sqrt{x-1}-\sqrt{x}(x-1)+\sqrt{x^2-x}=0$

$B.\ x^2+4x+5=2\sqrt{2x+3}$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងចូលមធ្យមសិក្សាកំរិតពីរវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ x-2\sqrt{x-1}-\sqrt{x}(x-1)+\sqrt{x^2-x}=0$

សមីការនេះមានន័យកាលណា: $x-1\geq 0\Rightarrow x\geq 1$

សមីការខាងលើអាចសរសេរ: $\Leftrightarrow\left(\sqrt{x-1}-1\right)^2+\sqrt{x(x-1)}\left(1-\sqrt{x-1}\right)=0$

$\Leftrightarrow\left(\sqrt{x-1}-1\right)\left(\sqrt{x-1}-1-\sqrt{x(x-1)}\right)=0$

$$\Leftrightarrow\left[\begin{array}{l}\sqrt{x-1}=1\\ \sqrt{x-1}-1-\sqrt{x(x-1)}=0\end{array}\right.$$

+ចំពោះ $\sqrt{x-1}=1\Rightarrow x=2$

+ចំពោះ $\sqrt{x-1}-1-\sqrt{x(x-1)}=0$ យើងតាង:

$f=\sqrt{x-1}-1-\sqrt{x(x-1)};x\geq 1$

$$\Rightarrow f'=\frac{1}{2\sqrt{x-1}}-\frac{2x-1}{2\sqrt{x(x-1)}}=\frac{\sqrt{x}-2x+1}{2\sqrt{x(x-1)}}<0\,\forall x\geq 1$$

$\Rightarrow f_{\max}=f(1)=-1<0$

$\Rightarrow f<0\,\forall x\geq 1$ មិនយកព្រោះមិនផ្ទៀងផ្ទាត់លក្ខខណ្ឌ

ដូចនេះគេបានសមីការមានរឹស: $x=2$ ។

យើងមានសមីការ: $B.\ x^2+4x+5=2\sqrt{2x+3}$

សមីការនេះមានន័យកាលណា: $2x+3\geq 0\Rightarrow x\geq -\frac{3}{2}$

យើងតាង: $t=\sqrt{2x+3}\,;t\geq 0\Rightarrow t^2=2x+3\Rightarrow x=\frac{1}{2}\left(t^2-3\right)$

នោះសមីការខាងលើទៅជា: $\frac{1}{4}\left(t^2-3\right)^2+2\left(t^2-3\right)+5=2t$

$\Leftrightarrow t^4+2t^2-8t+5=0\Leftrightarrow (t-1)\left(t^3+t^2+3t+5\right)=0$

$\Leftrightarrow\left[\begin{array}{l} t=1 \\ t^3+t^2+3t+5=0 \text{ មិនពិតចំពោះ}\forall t\geq 0\end{array}\right.$

$\Rightarrow t=1$

$+$បើ $t=1\Leftrightarrow\sqrt{2x+3}=1\Rightarrow x=-1$

ដូចនេះគេបានសមីការមានរឹស: $x=-1$ ។

**លំហាត់ទី២៤:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x+\sqrt{4-x^2}=2+3x\sqrt{4-x^2}$

$B.\ x^2+3x+1=(x-3)\sqrt{x^2+1}$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងសិស្សពូកែ***

## ចំលើយ

យើងមានសមីការ: $A.\ x+\sqrt{4-x^2}=2+3x\sqrt{4-x^2}$

សមីការនេះមានន័យកាលណា: $-2 \le x \le 2$ យើងតាង:

$t = x + \sqrt{4-x^2}; |t| \le 2\sqrt{2}$

$\Rightarrow t^2 = 4 + 2x\sqrt{4-x^2} \Rightarrow x\sqrt{4-x^2} = \frac{1}{2}(t^2-4)$

យើងបានសមីការខាងលើទៅជា: $t = 2 + \frac{3}{2}(t^2-4) \Leftrightarrow 3t^2 - 2t - 8 = 0$

$\Leftrightarrow \left[\begin{array}{l} t = -\frac{4}{3} \\ t = 2 \end{array}\right.$ យើងពិនិត្យចំពោះករណីនីមួយៗ

+បើ $t = -\frac{4}{3} \Leftrightarrow x + \sqrt{4-x^2} = -\frac{4}{3} \Leftrightarrow \sqrt{4-x^2} = -x - \frac{4}{3}$

$$\Leftrightarrow \left[\begin{array}{l} -x-\frac{4}{3} \ge 0 \\ 4-x^2 = x^2 + \frac{8}{3}x + \frac{16}{9} \end{array}\right. \Leftrightarrow \begin{cases} -2 \le x \le -\frac{4}{3} \\ 2x^2 + \frac{8}{3}x - \frac{20}{3} = 0 \end{cases} \Leftrightarrow \begin{cases} -2 \le x \le -\frac{4}{3} \\ \left[\begin{array}{l} x = \frac{-2-\sqrt{14}}{3} \\ x = \frac{14-2}{3} \text{ មិនយក} \end{array}\right. \end{cases}$$

+ចំពោះ $t = 2 \Leftrightarrow x + \sqrt{4-x^2} = 2 \Leftrightarrow \sqrt{4-x^2} = 2 - x$

$$\Leftrightarrow \begin{cases} x \le 2 \\ 4-x^2 = x^2 - 4x + 4 \end{cases} \Leftrightarrow \begin{cases} x \le 2 \\ \left[\begin{array}{l} x = 0 \\ x = 2 \end{array}\right. \end{cases} \Leftrightarrow \left[\begin{array}{l} x = 0 \\ x = 2 \end{array}\right.$$

ដូចនេះសមីការមានឫស: $x = 0 \vee x = 2 \vee x = \frac{-2-\sqrt{14}}{3}$ ។

យើងមានសមីការ: $B.\ x^2 + 3x + 1 = (x-3)\sqrt{x^2+1}$

យើងតាង: $t = \sqrt{x^2+1} \Rightarrow t^2 = x^2 + 1$ នោះសមីការខាងលើទៅជា:

$t^2-(x+3)t+3x=0$

$$\Delta=(x+3)^2-12x=(x-3)^2\Rightarrow\left[\begin{array}{l}t=\dfrac{x+3+x-3}{2}\\ t=\dfrac{x+3-x+3}{2}\end{array}\right.\Leftrightarrow\left[\begin{array}{l}t=x\\ t=3\end{array}\right.$$

+បើ $t=x\Rightarrow x^2+1=x^2$ មិនពិត

+បើ $t=3\Leftrightarrow x^2+1=9\Rightarrow x=\pm2\sqrt{2}$

ដូចនេះសមីការមានរឹស: $x=\pm2\sqrt{2}$ ។

**លំហាត់ទី២៥:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\sqrt{x+1}+\sqrt{4-x}+\sqrt{(x+1)(4-x)}=5$

$B.\sqrt[3]{x^2-7x+8}+\sqrt[3]{x^2-6x+7}-\sqrt[3]{2x^2-13x-12}=3$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងប្រជែងនៅប្រទេសបារាំង១៩៧០***

## ចំលើយ

យើងមានសមីការ: $A.\sqrt{x+1}+\sqrt{4-x}+\sqrt{(x+1)(4-x)}=5$

សមីការនេះមានន័យកាលណា: $-1\le x\le 4$

យើងតាង: $t=\sqrt{x+1}+\sqrt{4-x};t>0\Rightarrow t^2=5+2\sqrt{(x+1)(4-x)}$

នោះសមីការខាងលើទៅជា:

$$t+\frac{t^2-5}{2}=5\Leftrightarrow t^2+2t-15=0\Leftrightarrow\left[\begin{array}{l}t=-5 \text{ មិនយក}\\ t=3\end{array}\right.$$

+បើ $t=3 \Leftrightarrow \sqrt{x+1}+\sqrt{4-x}=3 \Leftrightarrow 5+2\sqrt{(x+1)(4-x)}=9$

$\Leftrightarrow (x+1)(4-x)=4 \Leftrightarrow \left[\begin{array}{l} x=0 \\ x=3 \end{array}\right.$

ដូចនេះសមីការមានរឹស: $x=0; x=3$ ។

យើងមានសមីការ: $B.\ \sqrt[3]{x^2-7x+8}+\sqrt[3]{x^2-6x+7}-\sqrt[3]{2x^2-13x-12}=3$

យើងតាង: $\begin{cases} a=\sqrt[3]{x^2-7x+8} \\ b=\sqrt[3]{x^2-6x+8} \\ c=-\sqrt[3]{2x^2-13x-12} \end{cases} \Rightarrow \begin{cases} a^3=x^2-7x+8 \\ b^3=x^2-6x+8 \\ c^3=-2x^2+13x+12 \end{cases}$

$\Rightarrow a^3+b^3+c^3=27$ ដោយសមីកាខាងលើ $a+b+c=3$

$\Leftrightarrow (a+b+c)^3=27$ នោះគេបាន: $(a+b+c)=a^3+b^3+c^3$

$\Leftrightarrow (a+b)(b+c)(c+a)=0 \Leftrightarrow \left[\begin{array}{l} a=-b \\ b=-c \\ c=-a \end{array}\right.$

+បើ $a=-b \Leftrightarrow \sqrt{x^2-7x+8}=-x^2+6x-7 \Leftrightarrow x^2-7x+8=-x^2+6x-7$

$\Leftrightarrow 2x^2-13x+15=0 \Leftrightarrow \left[\begin{array}{l} x=\dfrac{3}{2} \\ x=5 \end{array}\right.$

+បើ $b=-c \Leftrightarrow \sqrt[3]{x^2-6x+7}=\sqrt[3]{2x^2-13x-12}$

$\Leftrightarrow x^2-6x+7=2x^2-13x-12 \Leftrightarrow x^2-7x-19=0$

$\Leftrightarrow \left[\begin{array}{l} x=\dfrac{7-5\sqrt{5}}{2} \\ x=\dfrac{7+5\sqrt{5}}{2} \end{array}\right.$

+បើ $c=-a \Leftrightarrow \sqrt{2x^2-13x-12}=\sqrt{x^2-7x+8} \Leftrightarrow x^2-6x-20=0$

$$\Leftrightarrow \left[\begin{array}{l} x=3-\sqrt{29} \\ x=3+\sqrt{29} \end{array}\right.$$

ដូចនេះសមីការមានរឹស: $x=\frac{3}{2}; x=5; x=\frac{7\pm5\sqrt{5}}{2}; x=3\pm\sqrt{29}$ ។

**លំហាត់ទី២៦:** ចូរដោះស្រាយសមីការខាងក្រោម:

$A.10\sqrt[3]{x^3+8}=3\left(x^2-x+6\right)$

$B.x^3+\sqrt{\left(1-x^2\right)^3}=x\sqrt{2\left(1-x^2\right)}$

***ដកស្រង់ពីលំហាត់ប្រលងនៅប្រទេសសូវៀត***

## ចំលើយ

យើងមានសមីការ: $A.10\sqrt[3]{x^3+8}=3\left(x^2-x+6\right)$

សមីការនេះមានន័យកាលណា: $x\geq 2$ សមីការនេះអាចសរសេរ:

$$\Leftrightarrow 10\sqrt{(x+2)\left(x^2-2x+4\right)}=3\left(x^2-x+6\right)$$

យើងតាង:

$$\begin{cases} a=\sqrt{x+2}\geq 0 \\ b=\sqrt{x^2-2x+4}>0 \end{cases} \Rightarrow \begin{cases} a^2=x+2 \\ b^2=x^2-2x+4 \end{cases} \Rightarrow a^2+b^2=x^2-x+6$$

នោះសមីការខាងលើទៅជា: $10ab=3\left(a^2+b^2\right)\Leftrightarrow 3a^2-10ab+3b^2=0\Leftrightarrow\left[\begin{array}{l}a=\frac{b}{3}\\ a=3b\end{array}\right.$

+បើ $a=\frac{b}{3}\Leftrightarrow 3\sqrt{x+2}=\sqrt{x^2-2x+4}\Leftrightarrow 9\left(x+2\right)=x^2-2x+4$

$$\Leftrightarrow x^2-11x-14=0\Leftrightarrow\left[\begin{array}{l}x=\frac{11-\sqrt{177}}{2}\\ x=\frac{11+\sqrt{177}}{2}\end{array}\right.$$

+បើ $a=3b\Leftrightarrow\sqrt{x+2}=3\sqrt{x^2-2x+4}\Leftrightarrow x+2=3\left(x^2-2x+4\right)$

$\Leftrightarrow 9x^2-19x+34=0$ គ្មានរឹស

ដូចនេះសមីកាមានរឹស: $x=\frac{11\pm\sqrt{177}}{2}$ ។

យើងមានសមីការ: $B.\,x^3+\sqrt{\left(1-x^2\right)^3}=x\sqrt{2\left(1-x^2\right)}$

សមីការនេះមានន័យកាលណា: $1-x^2\ge 0\Leftrightarrow -1\le x\le 1$

យើងតាង: $x=\cos t;t\in\left[0;\pi\right]\Rightarrow\sin t\ge 0$ នោះសមីការខាងលើទៅជា:

$$\cos^3 t+\sqrt{\left(1-\cos^2 t\right)^3}=\cos t\sqrt{2\left(1-\cos^2 t\right)}$$

$$\Leftrightarrow\cos^3 t+\sin^3 t=\sqrt{2}\cos t.\sin t$$

$$\Leftrightarrow\left(\cos t+\sin t\right)\left(1-\sin t\cos t\right)=\sqrt{2}\sin t\cos t$$

យើងតាង: $y=\sin t+\cos t=\sqrt{2}\sin\left(t+\frac{\pi}{4}\right);\ 0\le t\le\pi;\ y\in\left[-1,\sqrt{2}\right]$

នោះសមីការខាងលើទៅជា: $y\left(1-\frac{y^2-1}{2}\right)-\sqrt{2}\,\frac{y^2-1}{2}=0$

$$\Leftrightarrow y\left(3-y^2\right)-\sqrt{2}\left(y^2-1\right)=0$$

$$\Leftrightarrow y^3+\sqrt{2}y^2-3y-\sqrt{2}=0$$

$$\Leftrightarrow \left(y-\sqrt{2}\right)\left(y^2+2\sqrt{2}y+1\right)=0$$

$$\Leftrightarrow \left[\begin{array}{l} y=\sqrt{2} \\ y^2+2\sqrt{2}y+1=0 \end{array}\right. \Leftrightarrow \left[\begin{array}{l} y=\sqrt{2} \\ y=-\sqrt{2}-1 \text{ មិនយក} \\ y=-\sqrt{2}+1 \end{array}\right.$$

+បើ $y=\sqrt{2}\Leftrightarrow\sqrt{2}\sin\left(t+\dfrac{\pi}{2}\right)=\sqrt{2}\Leftrightarrow t=\dfrac{\pi}{4}+2\pi k$

$\Rightarrow x=\cos t=\dfrac{\sqrt{2}}{2}$

+បើ $y=-\sqrt{2}+1\Leftrightarrow\sqrt{2}\sin\left(t+\dfrac{\pi}{2}\right)=-\sqrt{2}+1\Leftrightarrow\sin t+\cos t=1-\sqrt{2}$

$$\left(\sin t=\sqrt{1-\cos^2 t}=\sqrt{1-x^2}\right)$$

$$\Leftrightarrow\sqrt{1-x^2}=1-\sqrt{2}-x\Leftrightarrow\begin{cases} x\le 1-\sqrt{2} \\ 1-x^2=3-2\sqrt{2}-2\left(1-\sqrt{2}\right)x+x^2 \end{cases}$$

$$\Leftrightarrow\begin{cases} -1\le x\le 1-\sqrt{2} \\ 2x^2-2\left(1-\sqrt{2}\right)x+2-2\sqrt{2}=0 \end{cases}\Leftrightarrow x=\frac{1-\sqrt{2}-\sqrt{2\sqrt{2}-1}}{2}$$

ដូចនេះសមីការមានឫស: $x=\dfrac{\sqrt{2}}{2}\vee x=\dfrac{1-\sqrt{2}-\sqrt{2\sqrt{2}-1}}{2}$ ។

" កូនល្អស្តាប់ម៉ែ សិស្សពូកែស្តាប់គ្រូ"

**លំហាត់ទី២៧:** ចូរដោះស្រាយសមីការខាងក្រោម:

$$A.\frac{1}{x}+\frac{1}{\sqrt{1-x^2}}=\frac{35}{12}$$

$$B.\sqrt{1+\sqrt{1-x^2}}\left[\sqrt{(1+x)^3}-\sqrt{(1-x)^3}\right]=\frac{2}{\sqrt{3}}+\sqrt{\frac{1-x^2}{3}}$$

***ដកស្រង់ចេញពីការប្រលងសិស្សពូកែអន្តរជាតិ***

## ចំលើយ

យើងមានសមីការ: $A.\frac{1}{x}+\frac{1}{\sqrt{1-x^2}}=\frac{35}{12}$

សមីការនេះមានន័យកាលណា: $-1<x<1 \vee x\neq 0$

យើងតាង: $x=\cos t; 0<t<\pi \vee t\neq \frac{\pi}{2}$

នោះសមីការខាងលើទៅជា: $\frac{1}{\cos t}+\frac{1}{\sqrt{1-\cos^2 t}}=\frac{35}{12} \Leftrightarrow \frac{1}{\cos t}+\frac{1}{\sin t}=\frac{35}{12}$

$\Leftrightarrow 12(\sin t+\cos t)-35\sin t\cos t=0\,(*)$

យើងតាង: $y=\sin t+\cos t; -1<y<\sqrt{2} \vee y\neq 1$ នោះសមីការទៅជា:

$$12y-35\frac{y^2-1}{2}=0 \Leftrightarrow 35y^2-24y-35=0 \Leftrightarrow \left[\begin{array}{l} y=-\frac{5}{7} \\ y=\frac{7}{5} \end{array}\right.$$

$+$បើ $y=-\frac{5}{7} \Leftrightarrow \sin t+\cos t=-\frac{5}{7} \Leftrightarrow x+\sqrt{1-x^2}=-\frac{5}{7}$

$$\Leftrightarrow \sqrt{1-x^2} = -\frac{5}{7} - x \Leftrightarrow \left[\begin{array}{l} -1 < x \le -\frac{5}{7} \\ 1 - x^2 = x^2 + \frac{25}{49} + \frac{10}{7}x \end{array}\right.$$

$$\Leftrightarrow \begin{cases} -1 < x \le -\frac{5}{7} \\ 2x^2 + \frac{10}{7}x - \frac{24}{49} = 0 \end{cases} \Leftrightarrow x = \frac{-5-\sqrt{73}}{14}$$

+បើ $y = \frac{7}{5} \Leftrightarrow \sin t + \cos t = \frac{7}{5} \Leftrightarrow x + \sqrt{1-x^2} = \frac{7}{5}$

$$\Leftrightarrow \sqrt{1-x^2} = \frac{7}{5} - x \Leftrightarrow \begin{cases} x \le \frac{7}{5} \\ 1 - x^2 = x^2 - \frac{14}{5}x + \frac{49}{25} \end{cases}$$

$$\Leftrightarrow \begin{cases} -1 < x \le \frac{7}{5} \\ 2x^2 - \frac{14}{5}x + \frac{24}{25} = 0 \end{cases} \Rightarrow \left[\begin{array}{l} x = \frac{3}{5} \\ x = \frac{4}{5} \end{array}\right.$$

ដូចនេះសមីការមានរឹស: $x = \frac{-5-\sqrt{73}}{14} \vee x = \frac{3}{5}; x = \frac{4}{5}$ ។

យើងមានសមីការ: $B.\sqrt{1+\sqrt{1-x^2}}\left[\sqrt{(1+x)^3} - \sqrt{(1-x)^3}\right] = \frac{2}{\sqrt{3}} + \sqrt{\frac{1-x^2}{3}}$

សមីការនេះមានន័យកាលណា: $-1 \le x \le 1$

យើងតាង: $x = \cos t; 0 \le t \le \pi \Rightarrow \sin t \ge 0$ នោះសមីការមានន័យកាលណា:

$$\sqrt{1+\sqrt{1-\cos^2 t}}\left[\sqrt{(1+\cos t)^3} - \sqrt{(1-\cos t)^3}\right] = \frac{2}{\sqrt{3}} + \sqrt{\frac{1-\cos^2 t}{3}}$$

$$\Leftrightarrow 2\sqrt{1+\sin t}\sqrt{2}\left(\cos^3\frac{t}{2} - \sin^3\frac{t}{2}\right) = \frac{2}{\sqrt{3}} + \frac{\sin t}{\sqrt{3}}$$

$$\Leftrightarrow 2\sqrt{2}\left(\cos\frac{t}{2}+\sin\frac{t}{2}\right)\left(\cos\frac{t}{2}-\sin\frac{t}{2}\right)\left(1+\sin\frac{t}{2}\cos\frac{t}{2}\right)=\frac{2+\sin t}{\sqrt{3}}$$

$$\Leftrightarrow 2\sqrt{6}\cos t\left(1+\frac{1}{2}\sin t\right)=2+\sin t$$

$$\Leftrightarrow 2\sqrt{6}\cos t(2+\sin t)-2(2+\sin t)=0$$

$$\Leftrightarrow (2+\sin t)\left(\sqrt{6}\cos t-1\right)=0$$

$$\Leftrightarrow \cos t=\frac{1}{\sqrt{6}}\Rightarrow x=\frac{1}{\sqrt{6}}$$

ដូចនេះសមីការមានរឹស: $x=\dfrac{1}{\sqrt{6}}$ ។

**លំហាត់ទី២៨:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ \sqrt{1-x^2}+2\sqrt[3]{1-x^2}=3$

$B.\ 64x^6-112x^4+56x^2-7=2\sqrt{1-x^2}$

***ដកស្រង់ចេញពីវិញ្ញាសាត្រៀមប្រលងចូលមហាវិទ្យាល័យវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ \sqrt{1-x^2}+2\sqrt[3]{1-x^2}=3$

សមីការនេះមានន័យកាលណា: $-1\le x\le 1$ យើងតាង:

$x=\sin t; -\dfrac{\pi}{2}\le t\le\dfrac{\pi}{2}\Rightarrow \sin t\ge 0$ នោះសមីការខាងលើទៅជា:

$\sqrt{1-\sin^2 t}+2\sqrt[3]{1-\sin^2 t}=3\Leftrightarrow \cos t+2\sqrt[3]{\cos^2 t}-3=0$

យើងតាង: $y=\sqrt[3]{\cos^2 t}; 0\le y\le 1\Rightarrow \cos t=y^3\Leftrightarrow \sqrt[3]{\cos^2 t}=y^2$

នោះសមីការនេះទៅជា: $y^3+2y^2-3=0\Leftrightarrow (y-1)\left(y^2+3y+3\right)=0$

$\Leftrightarrow y=1 \Leftrightarrow \cos t=1 \Rightarrow x=0$

ដូចនេះសមីការមានរឹស: $x=0$ ។

យើងមានសមីការ: $B.64x^6-112x^4+56x^2-7=2\sqrt{1-x^2}$

សមីការនេះមានន័យកាលណា: $-1\le x\le 1$

យើងតាង: $x=\cos t;\ t\in[0;\pi]$ នោះសមីការខាងលើទៅជា:

$64\cos^6 t-112\cos^4 t+56\cos^2 t-7=2\sqrt{1-\cos^2 t}$

$\Leftrightarrow 64\cos^6 t-112\cos^4 t+56\cos^2 t-7=2\sin t$

$\Leftrightarrow 64\cos^7 t-112\cos^5 t+56\cos^3 t-7\cos t=2\sin t\cos t$

តាមរូបមន្ត: $\cos 3t=4\cos^3 t-3\cos t$ និង $\sin 3t=3\sin t-4\sin^3 t$

នោះគេបាន: $\cos 4t=\cos(3t+t)=8\cos^4 t-8\cos^2 t+1$

$\cos 5t=\cos(4t+t)=16\cos^5 t-20\cos^3 t+5\cos t$

$\cos 6t=\cos(5t+t)=32\cos^6 t-48\cos^4 t+18\cos^2 t-1$

$\cos 7t=\cos(6t+t)=64\cos^7 t-112\cos^5 t+56\cos^3 t-7\cos t$

នោះសមីការខាងលើទៅជា: $\cos 7t=\sin 2t=\cos\left(\frac{\pi}{2}-2t\right)$

$$\Leftrightarrow \left[\begin{array}{l} 7t=\frac{\pi}{2}-2t+2k\pi \\ 7t=2t-\frac{\pi}{2}+2k\pi \end{array}\right. \Leftrightarrow \left\{\begin{array}{l} t=\frac{\pi}{18}+\frac{2k\pi}{9} \\ t=-\frac{\pi}{2}+\frac{2k\pi}{5} \end{array}\right.$$

+បើ $t=\frac{\pi}{18}+\frac{2k\pi}{9};0\le t\le\pi \Rightarrow 0\le\frac{\pi}{18}+\frac{2k\pi}{9}\le\pi \Leftrightarrow -\frac{1}{4}\le x\le\frac{17}{4}$

$\Rightarrow m\in\{0;1;2;3;4\} \Rightarrow t\in\left\{\frac{\pi}{18};\frac{5\pi}{18};\frac{\pi}{2};\frac{13\pi}{18};\frac{17\pi}{18}\right\}$

ដោយ $\cos t\ne 0 \Rightarrow t\ne\frac{\pi}{2}$ នោះចំលើយខាងលើដែលផ្ទៀងផ្ទាត់:

$x=\cos\frac{\pi}{18};x=\cos\frac{5\pi}{18};x=\cos\frac{13\pi}{18};x=\cos\frac{17\pi}{18}$

+បើ $t=-\frac{\pi}{2}+\frac{2k\pi}{5};0\le -\frac{\pi}{2}+\frac{2k\pi}{5}\le\pi\Leftrightarrow\frac{1}{4}\le k\le\frac{11}{4}$

$\Rightarrow m=\{1;2\}\Rightarrow t\in\left\{\frac{3\pi}{10};\frac{7\pi}{10}\right\}\Rightarrow x=\cos\frac{3\pi}{10};x=\cos\frac{7\pi}{10}$

ដូចនេះសមីការមានរឹស:

$x=\cos\frac{\pi}{18};x=\cos\frac{3\pi}{10};x=\cos\frac{5\pi}{18};x=\cos\frac{7\pi}{10};x=\cos\frac{13\pi}{18};x=\cos\frac{17\pi}{18}$ ។

**លំហាត់ទី២៩:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ x^2+3\sqrt{x^2-1}=\sqrt{x^4-x^2+1}$

$B.\ \left(\sqrt{x^2+1}+2\right)^4+\left(\sqrt{x^2+1}-4\right)^4=272$

***ដកស្រង់ចេញពីវិញ្ញាសាប្រលងចូលមហាវិទ្យាល័យវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ x^2+3\sqrt{x^2-1}=\sqrt{x^4-x^2+1}$

សមីការនេះមានន័យកាលណា: $x^2-1\ge 0\Leftrightarrow |x|\ge 1$

យើងតាង: $x=\frac{1}{\cos t};t\in\left[0;\frac{\pi}{2}\right)\cup\left[\frac{\pi}{2};\pi\right)$ នោះសមីការខាងលើទៅជា:

$$\frac{1}{\cos^2 t}+3\sqrt{\frac{1}{\cos^2 t}-1}=\sqrt{\frac{1}{\cos^4 t}-\frac{1}{\cos^2 t}+1}$$

$\Leftrightarrow 1+\tan^2 t+3|\tan t|=\sqrt{(1+\tan^2 t)^2-(1+\tan^2 t)+1}$

$\Leftrightarrow \tan^2 t+3|\tan t|+1=\sqrt{\tan^4 t+\tan^2 t+1}$

យើងតាង: $y=|\tan t|; y\geq 0$ នោះសមីការខាងលើទៅជា:

$y^2+3y+1=\sqrt{y^4+y^2+1}$ (*)

ដោយ: $y^4+3y+1=(y^2+1)^2-y^2=(y^2-y+1)(y^2+y+1)$

នោះសមីការ(*) ទៅជា:

$2\sqrt{(y^2+y+1)^2}-\sqrt{(y^2-y+1)^2}=\sqrt{(y^2-y+1)(y^2+y+1)}$

$$\Leftrightarrow 2\sqrt{\frac{y^2+y+1}{y^2-y+1}}-\sqrt{\frac{y^2-y+1}{y^2+y+1}}=1$$

យើងតាង: $u=\sqrt{\frac{y^2+y+1}{y^2-y+1}}>0$ នោះសមីការខាងលើទៅជា:

$2u-\frac{1}{u}-1=0\Leftrightarrow 2u^2-u-1=0\Rightarrow \left[\begin{array}{l} u=1 \\ u=-\frac{1}{2} \text{ មិនយក} \end{array}\right.$

+បើ $u=1\Leftrightarrow \frac{y^2+y+1}{y^2-y+1}=1\Leftrightarrow y=0\Rightarrow \tan t=0\Rightarrow t=0\vee t=\pi$

$\Rightarrow x=1\vee x=-1$

ដូចនេះសមីការមានរឹស: $x=-1; x=1$ ។

យើងមានសមីការ: $B.\left(\sqrt{x^2+1}+2\right)^4+\left(\sqrt{x^2+1}-4\right)^4=272$

យើងតាង: $x=\tan t; t\neq \frac{\pi}{2}+k\pi\,(k\in IZ)$ នោះសមីការទៅជា:

$\left(\sqrt{1+\tan^2 t}+2\right)^4+\left(\sqrt{1+\tan^2 t}-4\right)^4=272$

$\Leftrightarrow \left(\frac{1}{|\cos t|}+2\right)^4+\left(\frac{1}{|\cos t|}-4\right)^4=272$

យើងតាង: $u=\frac{1}{|\cos t|}; u\ge 1$ នោះសមីការនេះទៅជា:

$(u+2)^4+(u-4)=272$ (*) យើងតាង: $y=u-1$ ដែល

$(y+3)^4-(y-3)^4=272 \Leftrightarrow 2y^4+108y^2-110=0$

$\Leftrightarrow \left[\begin{array}{l} y^2=1 \\ y^2=-\frac{110}{2} \text{ មិនយក} \end{array}\right. \Rightarrow y=1 \Rightarrow u=2$

$\Rightarrow \frac{1}{\cos^2 t}=4 \Rightarrow 1+\tan^2 t=4 \Rightarrow x^2=3 \Leftrightarrow x=\pm\sqrt{3}$

ដូចនេះសមីករមានរឹស: $x=\pm\sqrt{3}$ ។

**លំហាត់ទី៣០:** ចូរដោះស្រាយសមីការខាងក្រោម:

$A.\ \frac{1}{1-\sqrt{1-x}}+\frac{1}{1+\sqrt{1+x}}=\frac{1}{\sqrt{1-x^2}}$

$B.\ x+\frac{x}{\sqrt{x^2-1}}=\frac{3\sqrt{5}}{2}$

***ដកស្រង់ចេញពីវិញ្ញាសាជ្រើសរើសសិស្សពូកែវៀតណាម***

## ចំលើយ

យើងមានសមីការ: $A.\ \frac{1}{1-\sqrt{1-x}}+\frac{1}{1+\sqrt{1+x}}=\frac{1}{\sqrt{1-x^2}}$

សមីការខាងលើមានន័យកាលណា: $-1<x<1$

យើងតាង: $x=\cos t; t\in(0;\pi)$ នោះសមីការទៅជា:

$$\frac{1}{1-\sqrt{1-\cos t}}+\frac{1}{1+\sqrt{1+\cos t}}=\frac{1}{\sqrt{1-\cos^2 t}}$$

$$\Leftrightarrow \frac{1}{1-\sqrt{2}\sin\frac{t}{2}}+\frac{1}{1+\sqrt{2}\cos\frac{t}{2}}=\frac{1}{\sin t}$$

$$\Leftrightarrow \frac{2+\sqrt{2}\left(\cos\frac{t}{2}-\sin\frac{t}{2}\right)}{1+\sqrt{2}\left(\cos\frac{t}{2}-\sin\frac{t}{2}\right)-\sin t}.\sin t=1$$

យើងតាង: $y=\cos\frac{t}{2}-\sin\frac{t}{2}=\sqrt{2}\cos\left(\frac{t}{2}+\frac{\pi}{4}\right)$ ដោយ $0<t<\pi$ និង

$y\in(-1;1)\Rightarrow y^2=1-\sin t\Rightarrow \sin t=1-y^2$ នោះសមីការខាងលើទៅជា:

$$\frac{\left(2+\sqrt{2}y\right)\left(1-y^2\right)}{1+\sqrt{2}y-\left(1-y^2\right)}=1\Leftrightarrow\left(2+\sqrt{2}y\right)\left(1-y^2\right)-y^2-\sqrt{2}y=0$$

$$\Leftrightarrow \sqrt{2}y^3+3y^2-2=0\Leftrightarrow\left(y-\frac{\sqrt{2}}{2}\right)\left(\sqrt{2}y^2+4y+2\sqrt{2}\right)=0$$

$$\Leftrightarrow\left[\begin{array}{l}y=\frac{\sqrt{2}}{2}\\ \sqrt{2}y^2+4y+2=0\end{array}\right.\Leftrightarrow\left[\begin{array}{l}y=\frac{\sqrt{2}}{2}\\ \left(y+\sqrt{2}\right)^2=0\end{array}\right.\Leftrightarrow\left[\begin{array}{l}y=\frac{\sqrt{2}}{2}\\ y=-\sqrt{2}\text{ មិនយក}\end{array}\right.$$

+យើងតាង: $y=\frac{\sqrt{2}}{2}\Rightarrow\sqrt{2}\cos\left(\frac{t}{2}+\frac{\pi}{4}\right)=\frac{\sqrt{2}}{2}\Leftrightarrow\cos\left(\frac{t}{2}+\frac{\pi}{4}\right)=\frac{1}{2}$

$$\Leftrightarrow\left[\begin{array}{l}\frac{t}{2}+\frac{\pi}{4}=\frac{\pi}{3}+2k\pi\\ \frac{t}{2}+\frac{\pi}{4}=-\frac{\pi}{3}+2k\pi\end{array}\right.(k\in IZ)\Leftrightarrow\left[\begin{array}{l}t=\frac{\pi}{6}+4k\pi\\ t=-\frac{7\pi}{6}+4k\pi\end{array}\right.$$

ដោយ $t\in(0;\pi)\Rightarrow t=\dfrac{\pi}{6}$ នោះ $x=\cos t=\dfrac{\sqrt{3}}{2}$

ដូចនេះសមីការមានឫស: $x=\dfrac{\sqrt{3}}{2}$ ។

យើងមានសមីការ: $B.\ x+\dfrac{x}{\sqrt{x^2-1}}=\dfrac{3\sqrt{5}}{2}$ សមីការមានន័យកាលណា: $|x|>1$

យើងតាង: $x=\dfrac{1}{\cos t};t\in\left(0;\dfrac{\pi}{2}\right)\cup\left(\dfrac{\pi}{2};\pi\right)$ នោះសមីការខាងលើទៅជា:

$$\frac{1}{\cos t}+\frac{\frac{1}{\cos t}}{\sqrt{\frac{1}{\cos^2 t}-1}}=\frac{3\sqrt{5}}{2}\Leftrightarrow\frac{1}{\cos t}+\frac{\frac{1}{\cos t}}{|\tan t|}=\frac{3\sqrt{5}}{2}(*)$$

+ចំពោះ $0<t<\dfrac{\pi}{2}$ នោះ $\tan t>0$ សមីការ $(*)\Leftrightarrow\dfrac{1}{\cos t}+\dfrac{1}{\sin t}=\dfrac{3\sqrt{5}}{2}$

$\Leftrightarrow 2(\sin t+\cos t)=3\sqrt{5}\sin t\cos t\,(**)$ យើងតាង:

$y=\sin t+\cos t=\sqrt{2}\sin\left(t+\dfrac{\pi}{4}\right)$ ដោយ $0<t<\dfrac{\pi}{2}\Rightarrow y=\left(1;\sqrt{2}\right]$

នោះសមីការ $(**)$ ទៅជា: $2y=\dfrac{3\sqrt{5}}{2}\left(y^2-1\right)\Leftrightarrow 3\sqrt{5}y^2-4y-3\sqrt{5}=0$

$\Leftrightarrow y=\dfrac{3}{\sqrt{5}}$ នោះតាម $(**)$ គេបាន: $\sin t\cos t=\dfrac{2}{3\sqrt{5}}.\dfrac{3}{\sqrt{5}}=\dfrac{2}{5}$

